# កម្ពុជាក្រោម

ព្រឹត្តិបត្របោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ១៣ ឆ្នាំទី ០២ - ខែមករា គ.ស. ២០០៥ - ព.ស. ២៥៤៨ - $N^0$ 13, January, 2005

# អង្គការ យូអិនភីអូ ស្វាគមន៍សមាជិកថ្មី ៦ ទៀត

**សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលជាសមាជិកនៃគណៈកម្មការកណ្តាល នៃអង្គការយូអិនភីអូ*

កិច្ចប្រជុំលើកទី ២៩ របស់គណៈកម្មការកណ្តាលនៃអង្គការប្រជាជាតិ ដែលគ្មានតំណាងនៅក្នុងអង្គការសហប្រជាជាតិ ហៅកាត់ថាយូអិនភីអូ បានប្រារព្ធធ្វើនៅទីក្រុងឡាអេ ប្រទេសហូឡង់ ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៤ ។ នៅក្នុងកិច្ចប្រជុំនេះមានសមាជិកចូលរួមជាច្រើនដូចជា ខ្មែរក្រោម, កាប៊ិនដា (Cabinda), ជិន (Chin), គ្រីមមីន ថាតា (Crimean Tatars), ហុ៊ងហ្គារាន នៅរ៉ូម៉ានៀ (Hungarians in Romania), ប៉ាពួខាងលិច (West Papua), គណៈប្រតិភូពី Ahwaza ប្រជាជាតិឌេននៃទន្លេក្របី (Buffalo River Dene Nation), អូរ៉ូមមូ (Oromo), និង កាំមើរ៉ូនខាងត្បូង (Southern Cameroons), រួមទាំងភ្ញៀវកិត្តិយសជាច្រើនទៀត ។

គណៈកម្មាការកណ្តាល ដែលបើកកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន គឺក្នុងគោលបំណងដើម្បីបូកសរុបការងារប្រចាំឆ្នាំ ២០០៤ និងរៀបចំផែនការប្រតិបត្តិការសម្រាប់ឆ្នាំ ២០០៥ នឹងដាក់ជូនអង្គមហាសន្និបាតពិភាក្សានៅ ៦ ខែខាងមុខនេះ ។ ការរៀបចំមហាសន្និបាតនេះឡើងក្នុងគោលបំណង ដើម្បីត្រួតពិនិត្យសារឡើងវិញ អំពីចំណុចសំខាន់ ៗ ដែលបានទទួលស្គាល់ដោយអគ្គលេខាធិការដ្ឋានដើម្បីរិះរកវិធីសាស្រ្តធ្វើឲ្យអង្គការដំណើរការកាន់តែមានប្រសិទ្ធភាព ។ ម្យ៉ាងទៀត ដើម្បីពិនិត្យនូវចំណុចមួយចំនួននៃសន្ធិសញ្ញា ដែលត្រូវបានផ្លាស់ប្តូរជាចាំបាច់ និងប្រតិបត្តិបរិបទបច្ចុប្បន្ន ហេតុនេះហើយ ទើបចំណុចទាំងនេះត្រូវបានលើកយកមកពិភាក្សាជាមួយសមាជិកទាំងឡាយ នៃអង្គការយូអិនភីអូ ។



ទិដ្ឋភាពអង្គសន្និបាត UNPO ថ្ងៃទី ១៧-១៩ ធ្នូ ២០០៤ នៅក្រុងឡាអេ

ក្នុងចំណោមបញ្ហាសំខាន់ ៗ មួយចំនួន សមាជិកទាំងឡាយបានពិភាក្សាអំពីស្ថានភាពនៅខាងជើងប្រទេសអៀរ៉ាក់ និងទំនាក់ទំនងរវាងសមាជិកអង្គការយូអិនភីអូដទៃទៀតនៅតំបន់នោះ និងលទ្ធភាពជួយក្នុងការបោះឆ្នោត ដែលនឹងខិតជិតមកដល់នៅពេលខាងមុខ នៅប្រទេសអៀរ៉ាក់ ។ សមាជិកទាំងអស់ មានក្តីសោមនស្សរីករាយនៅ ពេលដែលបានឮដូច្នេះ ។ លោក ហារីសចាង ទោះបីជាមានការងារ ដែលត្រូវធ្វើច្រើន នៅក្នុងតំណែង ១ ជាក្រុមប្រឹក្សាសន្តិសុខជាតិតៃវ៉ាន់យ៉ាងណា ក៏ដោយ ក៏លោកតែងពេញចិត្តជួយបំពេញការងារអស់ពីសមត្ថភាព ក្នុងនាមខ្លួនជាប្រធាននៃគណៈកម្មាធិការកណ្តាល នៃអង្គការ UNPO រហូតទាល់តែមហាសន្និបាត អង្គការសហប្រជាជាតិលើកទី ៤ ឈានមកដល់។

អង្គការយូអិនភីអូ សូមប្រកាសថាសមាជិកថ្មីទាំង ៦ នេះត្រូវបានទទួលស្គាល់ជាសមាជិកអង្គការ UNPO រួមមាន ៖ អូរ៉ូមមូ (The Oromo), កាំមើរ៉ូនខាងត្បូង (Southern Cameroons), ប្រជាជាតិឌេននៃទន្លេ ក្របី (Buffalo River Dene Nation), ម៉ាសៃ (Maasai), ណាហួស ឌែល អរតូ បាលសាស (Nahuas

## មាតិការឿង

-អង្គការយូអិនភីអូស្វាគមន៍......................១
-វិចារណកថា ប្រឆាំងអាណានិគម...........២
-សេចក្តីថ្លែងការណ៍ ក្រុងយ៉ាំងហ្គូន .........៣
-គណៈប្រតិភូព្រះសង្ឃខ្មែរក្រោម..............៤
-អំពើហិង្សាលើសិទ្ធិមនុស្ស.......................៦
-សុន្ទរកថាលោក ថាច់ តាន់តារា..............៨
-រឿងកំពប់តែអុង................................១០
-រឿងអាទិត្តរាជ....................................១៤



ពីឆ្វេងទៅស្តាំ លោក ត្រឹង យ៉ាប, លោក ថាច់ ង៉ុក ថាច់ និង លោក ថាច់ រៀន

ទីស្នាក់ការ ៖ P.O. Box 2569, Worcester, MA 01613, USA, Tel: (508) 922-4834, email: kkfnewsletter@khmerkrom.net, http://www.khmerkrom.net

del Alto Balsas), និង សូមាលីឡែន (Somaliland) ។ អង្គការយូអិនភីអូ សូមស្វាគមន៍សមាជិកថ្មីទាំងនេះ និងរង់ចាំការជួយជ្រោមជ្រែងការងារពីសមាជិកថ្មី ក្នុងអង្គការយូអិនភីអូ ។ ដូច្នេះបច្ចុប្បន្នអង្គការយូអិនភីអូមានសមាជិកសរុបចំនួន ៦០ ជាតិសាសន៍ ។

ក្នុងមហាសន្និបាតនេះដែរ សហព័ន្ធខ្មែរកម្ពុជាក្រោមមានគណៈប្រតិភូដឹកនាំដោយលោក ថាច់ ង៉ុកថាច់ ប្រធានប្រតិបត្តិ លោក ថាច់ វៀ តំណាងទ្វីបអឺរ៉ុប និងលោកត្រឹង យ៉ាប ជាអគ្គលេខាធិការចូលរួមផងដែរ ។ ក្នុងមហាសន្និបាតនេះ សហព័ន្ធខ្មែរកម្ពុជាក្រោម ត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មាធិការកណ្តាលនៃអង្គការយូអិនភីអូក្នុងពេលអនាគតឆាប់ ៗ នេះ ៕ VOKK

## វិចារណកថា

# ប្រឆាំងអាណានិគមយួនលើទ្វីបទាំង ៥

*សហព័ន្ធសូមអំពាវនាវខ្មែរក្រោមទូទាំងសកល ប្រកាន់នូវគោលជំហរជាតិពិត ៗ ។ សហព័ន្ធសូមស្វាគមន៍ជនរួមឈាមខ្មែរចូលរួមតស៊ូ ដើម្បីសេរីភាព ។ សហព័ន្ធសូមស្វាគមន៍ជនរួមឈាមខ្មែរចូលរួមតស៊ូ ដើម្បីប្រឆាំងនឹងរបបអាណានិគមយួន ។*

*ពេលណាយើងយល់ច្បាស់ កលល្បិចបំបែកបំបាក់ របស់យួនពេលនោះហើយយើងខ្មែរក្រោមនឹងមានសិទ្ធិបរិបូរ ដើម្បីសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ ពេលនោះហើយពន្លឺសេរីភាពប្រាកដជាមាន ។ ពេលណាខ្មែរក្រោមដឹងច្បាស់ថា សាមគ្គីគឺការរួបរួមគ្នាជាធ្លុងមួយ និយាយសំឡេងខ្មែរក្រោម ទឹកចិត្តខ្មែរក្រោម ពេលនោះហើយអន្តរជាតិនឹងគាំទ្រយើង ។ ពេលណាខ្មែរក្រោមយល់ថា សាមគ្គីគឺមានតែមួយ ពេលនោះហើយកលល្បិចយួនអស់មានប្រសិទ្ធភាពហើយ ។ ពេលណាខ្មែរក្រោមដឹងថា ការទាមទារដើម្បីសម្រេចវាសនាខ្លួនដោយខ្លួនឯង មិនមែនតែខ្មែរក្រោមប៉ុណ្ណោះទេ គឺមានជនជាតិរងគ្រោះរាប់រយនាក់ ក្រោកឡើងតស៊ូ ពេលនោះហើយ យួនមិនអាចបំបាក់ស្មារតីតស៊ូបានទៀតទេ ។ ពេលណាខ្មែរក្រោមបានដឹងថា មានអ្នកតស៊ូដើម្បីសម្រេចវាសនាខ្លួនដោយខ្លួនឯងមាននៅគ្រប់ទ្វីបទាំង ៥ ពេលនោះហើយសេចក្តីសង្ឃឹមលើការតស៊ូអហិង្សារបស់សហព័ន្ធ គឺពិតជាមានពន្លឺយ៉ាងត្រចះត្រចង់ ។*

*ពាក្យខ្មែរក្រោម ប្រវត្តិសាស្ត្រខ្មែរក្រោម ការរងគ្រោះរបស់ខ្មែរក្រោម អំពើឃាតកម្មរបស់អាណានិគមយួននឹងពុះកញ្ជ្រោលឡើងដូចភ្នំលើទ្វីបទាំង ៥ ។ ពាក្យខ្មែរក្រោមនឹងចូលពីត្រចៀកមួយទៅត្រចៀកមួយ ឮពីមាត់មួយទៅមាត់មួយ សេចក្តីស្រឡាញ់ អាណិត ស្រណោះនឹងគាំទ្រការតស៊ូអហិង្សា ប្រាកដមានវិសាលភាពមិនខានលើសកលលោក ។ ពេលណាអតីតកាលខ្មែរក្រោមត្រូវបានសង្គមពិភពលោកឃើញច្បាស់នោះ ដំណើរការតស៊ូបច្ចុប្បន្ន និងអនាគតរបស់ខ្មែរក្រោម មិននៅឯកោទៀតទេ ។ ពិភពលោក នឹងយកបញ្ហាខ្មែរក្រោមទៅដោះស្រាយ ពេលនោះវីរបុរសយើងនឹងជូនពរបវរសួស្តីដល់យើងមិនខាន ។*

*សូមខ្មែរក្រោមទូទាំងសកលលោក មេត្តានិយាយនូវរឿងសោកនាដកម្ម ដែលក្រុងហាណូយធ្វើមកលើខ្មែរក្រោម ។ សូមខ្មែរក្រោមទូទាំងសកល មេត្តាបំពេញភារកិច្ចរបស់ខ្លួនជាកូនខ្មែរ ។*

*សូមនិយាយអំពីអំពើអយុត្តិធម៌ ដែលក្រុងហាណូយរំលោភ សូមនិយាយពីអំពើប្រល័យពូជសាសន៍ សូមនិយាយពីបំណងរបស់ខ្មែរក្រោមនៅក្នុងស្រុក ។ល។ សង្គមពិភពលោកនៅទ្វីបទាំង ៥ នឹងយកចិត្តទុកដាក់ដឹងឮនូវសេចក្តីអំពាវនាវ ហើយខ្មែរក្រោមនឹងទទួលនូវការគាំទ្រទូទាំងសកល ។ **"សំដីជាអាវុធ ចិត្តបរិសុទ្ធជាចំណងសាមគ្គី"***

*ថ.ថាច់*

និពន្ធនាយក ៖ **ថាច់ ង៉ុក ថាច់** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, ថាច់ សែន, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# សេចក្តីថ្លែងការណ៍រួម

## សន្និសីទកំពូលស្តីពីព្រះពុទ្ធសាសនាពិភពលោក នៅថ្ងៃទី ០៩ ដល់ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០៤ នាទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា





*គណៈប្រតិភូព្រះសង្ឃខ្មែរកម្ពុជាក្រោម និមន្តចូលរួមពិភាក្សាជាមួយក្រុមស្តីអំពីវិស័យអប់រំ*

នៅក្នុងអបរិហានិយសូត្រ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ៖ ការឧស្សាហ៍ព្យាយាមប្រជុំរបស់ព្រះសង្ឃជាញឹកញាប់ ជាហេតុនាំមកនូវភាពល្អប្រសើរក្នុងសង្គមព្រះពុទ្ធសាសនា និងសង្គមសង្ឃ ។ សន្និសីទព្រះពុទ្ធសាសនា មុនបង្អស់ចាប់ពីសតវត្សរ៍ទី ៦ មុនគ្រឹស្តសករាជមកម្ល៉េះ។ សង្ឃសន្និបាតចំនួនពីរដង ត្រូវបានប្រារព្ធធ្វើឡើងនៅប្រទេសឥណ្ឌា ក្នុងសម័យព្រះពុទ្ធកាល ។ ប្រទេសឥណ្ឌាជាកន្លែង ដែលព្រះពុទ្ធអង្គទ្រង់ដឹកនាំព្រះសង្ឃ ឲ្យចេញទៅផ្សព្វផ្សាយព្រះពុទ្ធ–សាសនាគ្រប់ទិសទី ថែមទាំងបានតែងតាំងព្រះមហាថេរជាប្រមុខដឹកនាំ ដើម្បីភិបាលសង្ឃទៀតផង ។ បន្ទាប់ពីព្រះអង្គទ្រង់បរិនិព្វានទៅ សង្គាយនាជាច្រើនលើក ត្រូវបានព្រះមហាថេរទាំងឡាយ ប្រារព្ធធ្វើឡើង ដើម្បីផ្ទៀងផ្ទាត់ព្រះធម៌ព្រះវិន័យឲ្យត្រឹមត្រូវទៅតាមពុទ្ធវចនាដើម ។ សង្គាយនាបីដង លើកដំបូងប្រារព្ធធ្វើឡើងនៅប្រទេសឥណ្ឌាជាកន្លែងកំណើតនៃព្រះពុទ្ធសាសនា ។ ដោយអនុលោមទៅតាមសង្គាយនាលើកទី ៣ ព្រះពុទ្ធសាសនាបានប្រារព្ធផ្សាយទៅកាន់ប្រទេសនានាទូទាំងពិភពលោក ។ សង្គាយនាលើកទី ៤ បានធ្វើឡើងនៅប្រទេសស្រីលង្កា ជាសន្និសីទលើកទី ១ ក្រៅពីឥណ្ឌា ។ សង្គាយនាលើកទី ៥ ត្រូវបានធ្វើឡើងក្នុងឆ្នាំ ១៨៧១ នៅទីក្រុងបណ្ឌាលេនៃប្រទេសភូមា សន្និសីទលើកទី ៦ ត្រូវបានធ្វើឡើងនៅមហាគុហាបាសាទ ប្រទេសភូមាដែរ ក្នុងឆ្នាំ ១៩៥៦ ជាសន្និសីទលើកទី ១ ដែលមេដឹកនាំមកពីប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាថេរវាទទាំងអស់ មានតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងរៀបរៀងឡើងវិញនូវព្រះត្រៃបិដក ឲ្យត្រឹមត្រូវទៅតាមច្បាប់ដើម ។ មានព្រះសង្ឃមហាយានទាំងឡាយ មកពីប្រទេសនានា ដូចជាប្រទេសចិន ជប៉ុន ជាដើម បានចូលរួមនៅក្នុងមហាសន្និបាតនេះ ។ ការប្រជុំកំពូលព្រះពុទ្ធសាសនាពិភពលោកមួយ ត្រូវបានធ្វើឡើងនៅប្រទេសនេប៉ាល់ ក្នុងឧទ្យានឈ្មោះ លុម្ពិនី នាឆ្នាំ ១៩៩៨ ។ នៅឆ្នាំដូចគ្នានោះដែរ ការផ្តើមគំនិតរបស់និកាយនេនប៉ូសូស៊ូ សន្និសីទផ្សព្វផ្សាយព្រះពុទ្ធសាសនាពិភពលោលើកទី ១ ត្រូវបានធ្វើឡើងនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។ សន្និសីទផ្សព្វផ្សាយព្រះពុទ្ធសាសនាពិភពលោកលើកទី ២ នៅប្រទេសថៃ ក្នុងឆ្នាំ ២០០០ និងលើកទី ៣ ត្រូវបានធ្វើនៅប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០២ ។ នៅប្រទេសភូមាជាកន្លែងដែលព្រះពុទ្ធសាសនា រក្សានូវភាពដើម អស់រយៈកាលជាងមួយពាន់ឆ្នាំមកហើយ ។ សន្និសីទកំពូលព្រះពុទ្ធសាសនាពិភព–លោក បានប្រារព្ធនៅចំកន្លែងប្រវត្តិសាស្ត្រដ៏ធំឈ្មោះ មហាគុហាបាសាទ កប៉ាអេ នាទីក្រុងយ៉ាំងហ្គូន ពីថ្ងៃទី ០៩ ដល់ទី ១១ ធ្នូ ឆ្នាំ ២០០៤ នៅប្រទេសភូមា ។ ព្រះមហាថេរដ៏ល្បី ៗ និងប្រមុខរដ្ឋជាច្រើន បានចូលរួមអង្គសន្និសីទព្រះពុទ្ធសាសនាពិភពលោកដ៏សំខាន់នេះ ។

*គោលបំណងនៃអង្គសន្និសីទមានដូចជា ៖*

–ដើម្បីពង្រឹងមិត្តភាព ការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមពុទ្ធសាសនិកជនទាំងឡាយ ដែលមកពីប្រទេសផ្សេង ៗ គ្នានៃពិភពលោក ដើម្បីរក្សា

នូវពុទ្ធវចនៈ និងប្រតិបត្តិព្រះធម៌ ដើម្បីពង្រឹងនូវការអប់រំផ្នែកព្រះពុទ្ធសាសនា ដោយពឹងផ្អែកទៅលើការសិក្សាព្រះត្រៃបិដក ដើម្បីនាំមកនូវពិភពលោកមួយ ដែលមានសន្តិភាព និងដើម្បីផ្សព្វផ្សាយនូវពុទ្ធោវាទនៅក្នុងពិភពលោក ។

ជាទីបញ្ចប់នៃសេចក្តីថ្លែងការណ៍នេះ យើងជាអ្នកចូលរួមក្នុងសន្និសីទព្រះពុទ្ធសាសនាពិភពលោកជាប្រវត្តិសាស្ត្រនេះ បានយល់ព្រមយ៉ាងពេញទំហឹងនូវគោលបំណងដូចខាងក្រោម ៖

–យើងព្យាយាមពង្រឹង និងផ្សព្វផ្សាយនូវពុទ្ធោឱវាទ ។

–យើងព្យាយាមការពារ ថែរក្សា និងស្ដាបនានូវកេរដំណែលនៃព្រះពុទ្ធសាសនាទុកជាប្រវត្តិសាស្ត្រ ។

–យើងនាំគ្នាកសាងសន្តិភាព ភាពរីកចម្រើនរុងរឿងនៅក្នុងពិភពលោក ដោយការផ្សព្វផ្សាយទៅនូវពុទ្ធោវាទដ៏ឧត្តម ពោលគឺទឹកចិត្ត មេត្តា ករុណា មុទិតា និង ឧបេក្ខា ។

–យើងត្រូវតែរឹតចំណងសាមគ្គីភាព មិត្តភាព និងការពារ យោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកក្នុងចំណោមពុទ្ធបរិស័ទទាំងឡាយទូទាំងពិភពលោក ។

–យើងខិតខំប្រឹងប្រែងបណ្ដុះបណ្ដាល នូវប្រព័ន្ធអប់រំខាងផ្នែកពុទ្ធសាសនា ដោយប្រើវិធីសាស្ត្រទំនើប ៗ និងបច្ចេកវិទ្យាខ្ពស់ ។

–យើងឧស្សាហ៍នាំគ្នាប្រារព្ធនូវសន្និសីទ ស្ដីពីព្រះពុទ្ធសាសនាឲ្យបានញឹកញាប់ ដើម្បីផ្លាស់ប្ដូរយោបល់គ្នាទៅវិញទៅមកក្នុងគោលបំណងពង្រឹងនូវប្រាជ្ញាញាណ ។

–យើងនាំគ្នាប្រឹងប្រែងចែករំលែកនូវបញ្ញាញាណ ទាំងផ្នែកគន្ថធុរៈ និងវិបស្សនាធុរៈ ដល់មនុស្សលោកគ្រប់រូប ដើម្បីជាប្រយោជន៍នាំមកនូវសេចក្ដីសុខសន្តិភាពជូនពិភពលោកទាំងមូល ។

–យើងជឿជាក់ថា មជ្ឈមណ្ឌលព្រះពុទ្ធសាសនាទាំងឡាយ គួរតែស្ថាបនាឡើង នៅពាសពេញពិភពលោក ក្នុងគោលបំណងសាបព្រោះបណ្ដុះបណ្ដាលនូវឱវាទរបស់ព្រះពុទ្ធឲ្យបានរីកដុះដាលប្រសើរទ្វេឡើង ៕

*មហាគុហាបាសាទ កប៉ាអេ នៅទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា*

# ប្រវត្តិសាស្ត្រលើកដំបូងសម្រាប់ គណៈប្រតិភូសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម

គណៈប្រតិភូសហគមន៍ព្រះសង្ឃខ្មែរក្រោម បាននិមន្តចូលរួមមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក នៅសហភាពមីយ៉ាន់ម៉ា (ភូមា) នៅថ្ងៃទី ៩–១០–១១ ខែធ្នូ ឆ្នាំ ២០០៤ នាទីក្រុង រ៉ងហ្គូន ។

*សមាសភាពគណៈប្រតិភូ ៖*

–ព្រះតេជគុណ បញ្ញាវិសាលត្ថេរោ កាន់ សុផល តំណាងឲ្យព្រះតេជគុណ លីវ ពៅ ប្រធានសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម។

–ព្រះតេជគុណបញ្ញាជោតោ ថាច់ ប៊ីរង្គ តំណាងឲ្យព្រះសង្ឃខ្មែរក្រោមនៅទ្វីបអាមេរិក ។

–ព្រះតេជគុណវិសាលត្ថេរោ យៀង វណ្ណា ប្រធានសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

–ព្រះតេជគុណជោតញ្ញោណោ ចៅ សាង អនុប្រធានសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។




*គណៈប្រតិភូព្រះសង្ឃខ្មែរក្រោម ថតជាមួយព្រះតេជគុណ បណ្ឌិត មកពីប្រទេសឥណ្ឌា–អូស្ត្រាលី–ថៃ–ភូមា–ស្រីលង្កា និងប្រទេសអាមេរិក*

នៅក្នុងមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក យើងសង្កេតឃើញថាមានសម្ដេចព្រះសង្ឃរាជ រាជាគណៈ មន្ត្រីសង្ឃ ថ្នាក់ដឹកនាំព្រះពុទ្ធសាសនាកំពូល ៗ នាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ មន្ត្រីស្ថានទូត និងអង្គការនានា ដែលតំណាងឲ្យប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាជុំវិញពិភពលោកចំនួន ៣៧ ប្រទេសបានចូលរួម ។

*របៀបវារៈនៃអង្គមហាសន្និបាតមាន ៖*

ក–សុន្ទរកថាស្វាគមន៍របស់នាយករដ្ឋមន្ត្រី នៃប្រទេសភូមា ចំពោះគណៈប្រតិភូជាតិ និងអន្តរជាតិ ។

ខ–ព្រះតេជគុណ បណ្ឌិត ញ៉ានិស្សរៈ (Nynissara) ប្រធានអង្គមហាសន្និបាតប្រកាសបើកកម្មវិធី និងលើកយកប្រធានបទទាំង ៤ ចំណុចគឺ ៖

១–ព្រះពុទ្ធសាសនានិងការទំនាក់ទំនងស្ថានភាពពិភពលោក។

២–ការអប់រំ និងការការពារព្រះពុទ្ធសាសនា ។

៣–ការផ្សព្វផ្សាយ និងការលើកតម្កើងព្រះពុទ្ធសាសនា ។

៤–ការធ្វើសមាធិតាមរបៀបព្រះពុទ្ធសាសនា ដើម្បីសន្តិភាពលើពិភពលោក ។

អង្គមហាសន្និបាត បានប្រព្រឹត្តទៅតាមលំដាប់លំដោយនៃ

របៀបវារៈក្នុងលក្ខណៈថ្លៃថ្នូរ ។ ជាលើកដំបូងនៃទំព័រប្រវត្តិសាស្ត្រ សម្រាប់ព្រះសង្ឃខ្មែរក្រោម បានចូលរួមមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក ជាកិត្តិយស និងមោទនភាពយ៉ាងក្រៃលែងសម្រាប់សហគមន៍ព្រះសង្ឃខ្មែរក្រោម ដែលដឹកនាំដោយព្រះតេជគុណ លីវ ពៅ បានព្យាយាមទំនាក់ទំនងអង្គការពុទ្ធសាសនាពិភពលោករហូតទទួលបានជោគជ័យជាផ្លូវការ ។ បិតក្នុងបរិយាកាសដ៏ស្និទ្ធស្នាលនោះ ដោយការឧទ្ទេសនាមពីប្រធានអង្គមហាសន្និបាត ព្រះតេជគុណ ថាច់ ប៊ីរង្គ បានឡើងថ្លែងសង្ឃកថាស្តីពីការអប់រំ និងភូមិសាស្ត្រ ប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម ប្រគេន និងជូនអង្គមហាសន្និបាតសណ្តាប់ផងដែរ ជាងនេះទៅទៀត ព្រះតេជគុណបានសង្កត់ធ្ងន់ទៅលើស្ថានភាពព្រះពុទ្ធសាសនាព្រះសង្ឃខ្មែរក្រោម ដែលកំពុងរស់នៅក្រោមរបបអាណានិគមយួនសព្វថ្ងៃ និងសុំអំពាវនាវដល់អង្គមហាសន្និបាតមេត្តាជួយឧបត្ថម្ភផ្នែកអប់រំព្រះពុទ្ធសាសនាខ្មែរ នៅកម្ពុជាក្រោមយ៉ាងទទូច ។

ទន្ទឹមនឹងនោះដែរ គណៈប្រតិភូសហគមន៍ព្រះសង្ឃខ្មែរក្រោម ក៏បានចែកឯកសារភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និងរបាយការណ៍ស្តីពីសោកនាដកម្មនៅកម្ពុជាក្រោម ប្រគេន និងជូនដល់អង្គមហាសន្និបាតយ៉ាងច្រើន ។ តាមស្ថិតិពីគណៈកម្មការរៀបចំអង្គមហាសន្និបាត បានឲ្យដឹងថាព្រះសង្ឃ មន្ត្រីអ្នកមុខអ្នកការ មន្ត្រីស្ថានទូត និងអង្គការនានា ដែលបានចូលរួមប្រមាណជាង ៣០០០ អង្គនិងរូប ។ បន្ទាប់ពីព្រះតេជគុណ ថាច់ ប៊ីរង្គ បានថ្លែងសង្ឃកថារួចមក យើងសង្កេតឃើញបណ្តាគណៈប្រតិភូអន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំងមកលើគណៈប្រតិភូសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោមនៃយើង ជាពិសេសទៀតនោះ មានការចាប់អារម្មណ៍ពីព្រះតេជគុណបណ្ឌិត សត្យាបាល ជាអធិបតីតំណាងឲ្យពុទ្ធិកសកលវិទ្យាល័យនៅប្រទេសឥណ្ឌាទៀតផង ។ អង្គមហាសន្និបាតបានប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃ ទទួលបានលទ្ធផលជាវិជ្ជមាន សម្រាប់ផែនការនៃសង្គមព្រះពុទ្ធសាសនាពិភពលោក ជាមួយគ្នានោះដែរ ព្រះតេជគុណអធិបតី បានសរុបខ្លឹមសារនៃកិច្ចពិភាក្សា ដែលមានគោលបំណងដូចខាងក្រោម ៖

-ដើម្បីពង្រឹងមិត្តភាព ការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមពុទ្ធសាសនិកជនទាំងឡាយ ដែលមកពីប្រទេសផ្សេង ៗ គ្នានៃពិភពលោក ដើម្បីរក្សានូវពុទ្ធវចន និងប្រតិបត្តិព្រះធម៌ ដើម្បីពង្រឹងការអប់រំផ្នែកព្រះពុទ្ធសាសនា ដោយពឹងផ្អែកទៅលើការសិក្សាព្រះត្រៃបិដក ដើម្បីនាំមកនូវពិភពលោកមួយ ដែលមានសន្តិភាព និងដើម្បីផ្សព្វផ្សាយនៅពុទ្ធោវាទនៅក្នុងពិភពលោក ។

-យើងប្តេជ្ញាថែរក្សាពុទ្ធធម៌ ឲ្យស្ថិតនៅក្នុងភាពបរិសុទ្ធ ពោលគឺមិនដាក់បន្ថែម ឬ ក៏លុបចេញនូវពុទ្ធវចនៈណាមួយឡើយ ។

-យើងព្យាយាមពង្រឹង និងផ្សព្វផ្សាយនូវពុទ្ធោឱវាទ ។

-យើងព្យាយាមការពារ ថែរក្សា និង ស្តាបនានូវកេរដំណែលនៃពុទ្ធសាសនាទុកជាប្រវត្តិសាស្ត្រ ។

-យើងនាំគ្នាកសាងសន្តិភាព ភាពរីកចម្រើនរុងរឿងនៅក្នុងពិភពលោក ដោយការផ្សាយទៅនូវពុទ្ធោវាទដ៏ឧត្តម ពោលគឺទឹកចិត្តមេត្តា ករុណា មុទិតា និងឧបេក្ខា ។

-យើងត្រូវតែរឹតចំណងសាមគ្គីភាព មិត្តភាព និងយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក ក្នុងចំណោមពុទ្ធបរិស័ទទាំងឡាយទូទាំងពិភពលោក ។

-យើងខិតខំប្រឹងប្រែងបណ្តុះបណ្តាល នូវប្រព័ន្ធអប់រំខាងផ្នែកព្រះពុទ្ធសាសនា ដោយប្រើវិធីសាស្ត្រទំនើប ៗ និងបច្ចេកវិទ្យាខ្ពស់ ។

-យើងឧស្សាហ៍នាំគ្នា ប្រារព្ធនូវសន្និសីទស្តីពីព្រះពុទ្ធសាសនា ឲ្យបានញឹកញាប់ដើម្បីផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ក្នុងគោលបំណងពង្រឹងនូវប្រាជ្ញញាណ ។

-យើងនាំគ្នាប្រឹងប្រែងចែករំលែក នូវបញ្ញាញាណ ទាំងផ្នែកគន្ថធុរៈ និងវិបស្សនធុរៈ ដល់មនុស្សលោកគ្រប់រូប ដើម្បីជាប្រយោជន៍នាំមកនូវសេចក្តីសុខ សន្តិភាពជូនពិភពលោកទាំងមូល ។

-យើងជឿជាក់ថា មជ្ឈមណ្ឌលព្រះពុទ្ធសាសនាទាំងឡាយគួរតែស្ថាបនាឡើង នៅពាសពេញពិភពលោក ក្នុងគោលបំណងសាបព្រោះ បណ្តុះបណ្តាលនូវឱវាទរបស់ព្រះពុទ្ធឲ្យបានរីកដុះដាលប្រសើរទ្វេឡើងថែមទៀត ។

ជាពិសេសព្រះអង្គ បានសង្កត់ធ្ងន់លើការផ្សព្វផ្សាយ ការអប់រំតាមរយៈប្រព័ន្ធសម្ភារៈទំនើប ៗ ដូចជា ៖ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែតជាដើម ដល់បណ្តាប្រទេសជុំវិញពិភពលោក មានប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា ដែលពុទ្ធិកសាកលវិទ្យាល័យធំ ៗ ដូចជាប្រទេសភូមា-ថៃ-ស្រីលង្កា-ឥណ្ឌា និង ព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍ ដើម្បីឲ្យមានលក្ខណៈងាយស្រួល ក្នុងវិស័យសិក្សាស្រាវជ្រាវព្រះពុទ្ធសាសនា ឲ្យទាន់សម័យភាវូបនីយកម្មនៃវិទ្យាសាស្ត្រជឿនលឿន ។

នៅទីបញ្ចប់នៃអង្គមហាសន្និបាត ព្រះតេជគុណបណ្ឌិត ញ៉ានិស្សរៈ ប្រធានគណៈកម្មការរៀបចំមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក បានស្វាធ្យាយពុទ្ធជ័យមង្គល និងថ្លែងអំណរគុណ ព្រមទាំងប្រគេន-ជូនពរ ដល់គណៈប្រតិភូអន្តរជាតិទាំងអស់ទទួលបានជោគជ័យគ្រប់បេសកកម្ម ពិសេសចំពោះរដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា ដែលបានជួយឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងដល់អង្គមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក និងថ្លែងបិទកម្មវិធីនៃអង្គមហាសន្និបាត នៅវេលាម៉ោង ៣ និង ៣០ នាទីល្ងាច ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៤ ។

បន្ទាប់ពីអង្គមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក បានបញ្ចប់ទៅប្រកបដោយភាតរភាពនិងមិត្តភាពនោះមក គណៈប្រតិភូសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម បាននិមន្តទៅទស្សនកិច្ចកន្លែងសំខាន់ ៗ ជាប្រវត្តិសាស្ត្រនៃប្រទេសភូមា ក្នុងនោះមានកន្លែងសក្ការៈបូជាជាច្រើន មានសង្កុត្តចេតិយ ដែលមានអាយុកាលជាង ២០០០ ឆ្នាំ នាទីក្រុងរ៉ង់ហ្គូន ។ ហើយគណៈប្រតិភូសហគន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម បានការអនុញ្ញាតឲ្យចូលជួបព្រះតេជគុណបណ្ឌិត ញ៉ានិស្សរៈ និង មន្ត្រីមួយចំនួននៃប្រទេសភូមា។ ដោយមានការស្វាគមន៍យ៉ាងកក់ក្តៅពីព្រះតេជគុណបណ្ឌិត និងមន្ត្រីទាំងនោះ គណៈប្រតិភូយើងក៏បានលាតត្រដាង អំពីភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និង

វិស័យអប់រំនៅកម្ពុជាក្រោម ប្រគេនដល់ព្រះតេជគុណបណ្ឌិត និងមន្ត្រីទាំងនោះបានជ្រាបផងដែរ ។

ដំណើរសហប្រតិបត្តិការ នៃអង្គមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក ទទួលបានលទ្ធផលជោគជ័យជាប្រវត្តិសាស្ត្រ នោះគណៈប្រតិភូយើង បាននិមន្តទៅប្រទេសថៃ ដើម្បីសួរសុខទុក្ខសមណនិស្សិតខ្មែរក្រោម ដែលកំពុងបន្តការសិក្សានៅមហាវិទ្យាល័យនាទីក្រុងបាងកក ។

ស្របឱកាសនោះ សាស្ត្រាចារ្យអធិន្ទ្រៃយ៍នៃមហាវិទ្យាល័យពុទ្ធចក្រ ក៏បានអនុញ្ញាតឲ្យគណៈប្រតិភូសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម ឡើងថ្លែងសង្ឃកថារយៈពេលមួយម៉ោង ព្រះតេជគុណ ថាច់ ប៊ីវង្គ ក៏បានឡើងថ្លែងអំពីភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និងជំនឿព្រះពុទ្ធសាសនាខ្មែរនៅកម្ពុជាក្រោម ដែលរដ្ឋាភិបាលយៀកណាមធ្វើអាណានិគមលើប្រជាពលរដ្ឋខ្មែរក្រោម ដោយអយុត្តិធម៌ ប្រគេនជូនសមណនិស្សិត និងលោកសាស្ត្រាចារ្យបានជ្រាបជាលក្ខណៈស្មារតីជាតិ បន្ថែមពីនោះ ព្រះតេជគុណ កាន់ សុផល តំណាងឲ្យព្រះតេជគុណ លីវ ពៅ ប្រធានសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម ក៏បានឡើងរាយការណ៍អំពីសកម្មភាព និង ទិសដៅនៃសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោមជុំវិញពិភពលោកនាពេលអនាគត ។

សរុបសេចក្ដីមក អង្គមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក ដែលប្រារព្ធនៅ មហាគុហារ កប៉ាអេ នាទីក្រុងរ៉ង់ហ្គូន ប្រទេសភូមា គឺទទួលបានលទ្ធផលជោគជ័យ សម្រាប់ទិសដៅផែនការសន្តិភាព វឌ្ឍនភាព នៃទ្រឹស្ដីព្រះពុទ្ធវាទ ទូទាំងពិភពលោក ហើយជាព្រឹត្តិ–ការណ៍លើកដំបូងសម្រាប់ព្រះសង្ឃខ្មែរកម្ពុជាក្រោម បានចូលរួមមហាសន្និបាតលើឆាកអន្តរជាតិ នៃទំព័រប្រវត្តិសាស្ត្រខ្មែរក្រោម ៕

*ដោយភិក្ខុ បញ្ញាបជ្ជោតោ ថាច់ ប៊ីវង្គ*

# អំពើហឹង្សាលើសិទ្ធិមនុស្សយ៉ាងខ្លាំងក្លា ដែលត្រូវបានគេរាយការណ៍ចេញពីប្រទេសវៀតណាម

*ប្រព័ន្ធផ្សព្វផ្សាយ បានបញ្ចេញឲ្យដឹងកាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ ពីទីក្រុង* Spartanburg *សហរដ្ឋអាមេរិក ។*

*ប្រវត្តិសង្ខេប* ៖ កាលពីថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៤ ពួកកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ា ជាគ្រិស្តបរិស័ទចំនួន ១០ ពាន់នាក់ បានប្រារព្ធធ្វើបាតុកម្មដោយសន្តិវិធី ស្ថិតក្នុងភូមិភាគខ្ពង់រាបកណ្ដាលនៃប្រទេសវៀតណាម ដែលសូមអំពាវឲ្យរដ្ឋាភិបាលកុម្មុយនិស្តវៀត–ណាមបញ្ឈប់ការធ្វើទុក្ខទោសនានា ដែលបានធ្វើកន្លងមកអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ កងកម្លាំងសន្តិសុខរដ្ឋាភិបាលវៀតណាមបានវាយប្រហារយ៉ាងឃោរឃៅមកលើពួកបាតុករជាច្រើននាក់ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានបញ្ចេញ សេចក្ដីរាយការណ៍ឲ្យដឹងថា កាលពីថ្ងៃទី ២៨ ឧសភា ២០០៤ មានបាតុករជាច្រើនពាន់នាក់ត្រូវរងរបួស និងជាច្រើនពាន់នាក់ផ្សេងទៀតត្រូវគេសម្លាប់ចោល កាលពីថ្ងៃទី ១០ ទៅ ១១ មេសា តាមស្ពាន និងមហាវិថី ដែលឆ្ពោះចូលទៅក្នុងតំបន់បួនមេធួក ទីរួមខេត្តដាឡាក់ ត្រង់មជ្ឈមណ្ឌលឃុំសន្តិភាព ឃុំក្នុងខេត្តយ៉ាឡាយ និងខេត្តលឹមដុង ។

–រឿងរ៉ាវទាំងឡាយនៃជនរងគ្រោះទាំងពីររូប ស្ដីពីការសម្លាប់រង្គាល លើអ្នកធ្វើបុណ្យរំឭកថ្ងៃព្រះយេស៊ូគ្រិស្តរស់ឡើងវិញ "Easter Massacre" ត្រូវគេរៀបរាប់ឲ្យដឹងមានដូចខាងក្រោមនេះ ៖

រឿងរ៉ាវដែលគេកត់សម្គាល់សរសេរជាព័ត៌មាននេះ ដែលកើតចេញពីប្រភពនានាខាងក្នុងប្រទេសវៀតណាមដោយផ្ទាល់ ។ យើងសូមស្នើសុំថ្នាក់ដឹកនាំអន្តរជាតិនានា អញ្ជើញទៅកាន់ស្រុកភូមិទាំងនេះដោយផ្ទាល់ និងសូមជួយស៊ើបអង្កេតទៅលើបទឧក្រិដ្ឋទាំងអស់នោះផងដែរ ។

*ស្ត្រីមានផ្ទៃពោះម្នាក់ ដែលត្រូវអាជ្ញាធរវាយធ្វើទារុណកម្មដោយដំបងឆក់ ឥឡូវប្រសូត្របុត្រ ដែលស្លាប់ក្នុងពោះហើយ*

–អ្នកស្រី ហា ឡានី មកពីភូមិអ៊ីម៉ាប ស្រុក ជីម៉ា ខេត្តដាឡាក់ អ្នកស្រីមានគតិនៅពេលដែលអ្នកស្រី បានទៅ រួមធ្វើបាតុកម្មសន្តិភាព និងអហឹង្សា កាលពីថ្ងៃទី ១០–១១ ខែមេសា ២០០៤ នេះ អ្នកស្រីមិនបានជឿក្នុងចិត្តទាល់តែសោះថា រដ្ឋាភិបាលអមនុស្សធម៌ គ្មានមេត្តាធម៌ បានធ្វើទារុណកម្មទៅលើស្ត្រីមានផ្ទៃពោះ និងអ្នកដែលធ្វើបុណ្យរំឭកខួបព្រះយេស៊ូគ្រិស្ត និងសម្ដែងឆន្ទៈ ប៉ុន្តែពួកគេមិនមកតស៊ូវាយប្រហារជាមួយរដ្ឋាភិបាលវៀតណាមទេ ពួកគេមកនេះដោយសាតែសូត្រធម៌បួងសួងព្រះជាម្ចាស់ ដែលអ្នកស្រីផ្ទាល់សុំឲ្យបានតែសេចក្ដីសុខសុវត្ថិភាពផ្ទាល់ខ្លួនប៉ុណ្ណោះ ។ បាតុកម្មបានប្រារព្ធឡើងយ៉ាងស្ងៀមស្ងាត់ ដោយគ្រាន់តែមានបំណងសុំអំពាវនាវទៅដល់ក្រុមមន្ត្រីរដ្ឋាភិបាលថា ប្រជាជនម៉ុងតាញ៉ាសុំចង់ឲ្យមានអង្គការសិទ្ធិមនុស្សនៅតាមមូលដ្ឋានរបស់ពួកគេ និងសុំឲ្យមានសិទ្ធិជាប្រជាជនដើមដែលប្រទេសវៀតណាម ដែលត្រូវគោរពសិទ្ធិនេះ ។

–ក្នុងកំឡុងធ្វើទារុណកម្ម ប៉ូលិសបានចាប់អ្នកស្រី ហា ឡានី និងបានធ្វើទារុណកម្មអ្នកស្រីដោយវាយដំដោយដំបងឆក់យ៉ាងសាហាវ ។

ក្រោយមកអ្នកស្រីត្រូវគេដោះលែងវិញ ក៏ប៉ុន្តែសេចក្តីអន្តរាយត្រូវបានកើតឡើងរួចទៅហើយកាលពីថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៤ គឺអ្នកស្រីបានប្រសូតបុត្រស្លាប់ក្នុងផ្ទៃមួយរូប ដែលមាន ទម្ងន់ ៤ គីឡូក្រាម ។ ទង្វើឧក្រិដ្ឋប្រភេទនេះ មិនអាចអត់ឱនឲ្យបានឡើយ ហើយនេះអ្នកស្រីបានយំសោកពេញទៅដោយសេចក្តីឈឺចាប់ ទាំងផ្លូវកាយ និងផ្លូវចិត្ត ។

*-ការធ្វើទារុណកម្ម ការកាត់ទោស និងការចាប់ខ្លួន*

លោក អ៊ឹ រ៉ុងនី កើតនៅឆ្នាំ ១៩៦៨ នៅភូមិ-ឃុំខ្នា ស្រុកជឺម៉ា ខេត្តដាឡាក់ កាលពីថ្ងៃទី ១០-១១ ខែមេសា ២០០៤ លោកបានចូលរួមធ្វើបាតុកម្មសន្តិភាពមួយ ហើយបន្ទាប់មកគាត់បានត្រឡប់ទៅស្រុកវិញ ដោយគាត់បានគិតថា រដ្ឋាភិបាលវៀតណាមនឹងមិនធ្វើទុក្ខបុកម្នេញដល់រូបគាត់ទេ ប៉ុន្តែគាត់ត្រូវបានគេចោទប្រកាន់ថា មានកំហុស ។ កាលពីថ្ងៃទី ០២ ឧសភា ២០០៤ កងកម្លាំងប៉ូលីសមកពីក្រុងហាណូយ បានទៅដល់ផ្ទះរបស់គាត់ រួចចាប់ខ្លួនគាត់ ហើយនាំខ្លួនគាត់ចេញទៅបាត់តែម្តង បន្ទាប់មកគាត់ត្រូវគេកាត់ឲ្យមានទោស ហើយពួកប៉ូលីសបានប្រហាជីវិតគាត់ចោល ដោយហេតុតែគាត់មានជំនឿលើសាសនាគ្រិស្ត ។ ពួកគេបានបោះឈើឆ្កាង ហើយបានបោះដែកគោលលើរូបគាត់ឲ្យជាប់នឹងឈើឆ្កាងនោះ ។ ពួកគេបោះដែកគោលទៅនឹងជើងទាំង ២ អស់ចំនួន ៤ ដើម ដៃចំនួន ៤ ដើម ចំកណ្តាលដើមទ្រូង ១ ដើម ហើយបោះដែកគោលចំនួន ២ ដើមទៀតត្រង់ក្បាល ។ ៥ ថ្ងៃក្រោយមក ប៉ូលីសបាននាំយកក្តារម្ឈូសទៅជូនក្រុមគ្រួសាររបស់គាត់វិញ ដោយប្រាប់ក្រុមគ្រួសាររបស់គាត់ថា ពួកគេបានសម្លាប់រូបគាត់ ព្រោះគាត់បានប្រព្រឹត្តតាមលោក សរ កុក និងមូលនិធិម៉ុងតាញ៉ា ។ ក្រុមប៉ូលិសបានបញ្ជាឲ្យក្រុមគ្រួសាររបស់គាត់ទៅប្រមូលចំណែកសាកសព ដែលបានប្រហារនៅក្បែរចំការកាហ្វេ ហើយគំរាមកំហែងក្រុមគ្រួសារគាត់ថា កុំឲ្យប្រាប់នរណាពីការសម្លាប់គ្នាឡើយ បើមិនដូច្នេះទេ ពួកគេនឹងត្រឡប់មកវិញ ហើយសម្លាប់អ្នកទាំងអស់ជាមិនខាន ។ កាលពីថ្ងៃទី ០៩ ឧសភា ២០០៤ ក្រុមគ្រួសារលោក អ៊ឹ រ៉ុងនី (ជនរងគ្រោះ) បានអញ្ជើញទៅចំការកាហ្វេនោះ ហើយបានយកសាកសពរបស់គាត់ត្រឡប់មកកាន់ភូមិកំណើតវិញ ដោយមកបញ្ចុះសាកសពគាត់ដោយស្ងាត់ ៗ ។ អ្នកស្រុកភូមិខ្លះ បានរាយការណ៍ឲ្យយើងដឹងថា ពួកគេបានឃើញដោយផ្ទាល់ភ្នែកនូវឈើឆ្កាង ដែលជាកន្លែងលោក អ៊ឹ រ៉ុងនី ត្រូវបានគេធ្វើទារុណកម្មក្នុងចំការកាហ្វេ ។ នេះគឺជាព័ត៌មានចេញពីសាក្សីឃើញផ្ទាល់ក្នុងប្រទេសវៀតណាម ។

**សេចក្តីអំពាវនាវរបស់មូលនិធិម៉ុងតាញ៉ារួមមាន ៖**

-សហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ មេត្តាចាត់វិធានការជាបន្ទាន់ ដើម្បីស៊ើបអង្កេតនូវអំពើឧក្រិដ្ឋកម្មដ៏ច្បាស់ក្រឡែតនេះ ហើយសូមឲ្យរដ្ឋាភិបាលវៀតណាម មេត្តាដោះលែងប្រជាជនម៉ុងតាញ៉ារបស់យើង ដែលត្រូវគេចាប់ដាក់ក្នុងពន្ធនាគារពីបទចូលរួមសកម្មភាពនយោបាយសន្តិភាព និងពីហេតុផលកាន់សាសនាគ្រិស្ត ដោយតម្រូវឲ្យមានសំណងទឹកចិត្តយុត្តិធម៌មួយពីរដ្ឋាភិបាល ឬក៏សូមព្យាយាមជួយអ្នកដែលភៀសខ្លួនចូលមកកម្ពុជា ក្នុងឋានៈជាជនភៀសខ្លួន ។

-សហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ មេត្តាជួយចាត់វិធានការឲ្យភ្នាក់ងារសិទ្ធិមនុស្ស ចូលទៅដល់តំបន់ខ្ពង់រាបកណ្តាល ហើយសូមឲ្យចេញអនុសារណៈមួយ នៃគណៈកម្មាធិការអង្គការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិសេរីភាពមនុស្ស ដែលវៀតណាមបានបន្តការធ្វើមិនដឹងមិនឮ (របាយការណ៍សិទ្ធិមនុស្សនាសម័យប្រជុំទី ៧៥ ក្នុងខែកក្កដា ២០០២ ដែលរាប់បញ្ចូលមានទាំងការសង្កេតការណ៍នានាប្រចាំប្រទេសវៀតណាម ដោយអង្គការសហ-ប្រជាជាតិ doc: CCTR/CISR.2031) ។

សហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ មេត្តាជួយចាត់វិធានការជាបន្ទាន់ ដើម្បីធានាឲ្យឧត្តមស្នងការនៃអង្គការសហប្រជា-ជាតិទទួលបន្ទុកជនភៀសខ្លួន បានធ្វើប្រតិបត្តិការដោយសេរីក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម តាមអនុសញ្ញាស្តីពីជនភៀសខ្លួន (ប្រកាសដោយបេសកជនពិសេស នៃអង្គការសហប្រជាជាតិ លោក ភិតធីឡឺប្រ៊ិច នាពេលថ្មី ៗ នេះ) ។ សូមអង្គការសហប្រជាជាតិ ហើយនឹងបណ្តាប្រទេស ជាសមាជិកនៃអនុគណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលរបស់អង្គការសហប្រជាជាតិ បដិសេធនូវការចោទប្រកាន់ដែលប្រឌិតឡើងដោយរដ្ឋាភិបាលវៀតណាមប្រឆាំងនឹងលោក សរ កុក មូលនិធីម៉ុងតាញ៉ា និង គណៈបក្ស TRP (Transnational Radical Party) (សូមឲ្យអង្គការក្រៅរដ្ឋាភិបាល ជួយពិគ្រោះជាមួយអង្គការសហប្រជាជាតិ ដើម្បីអនុញ្ញាតឲ្យលោក សរ កុក បានថ្លែងបញ្ជាក់នូវបេសកម្មដែលបានធ្វើតែពាក់កណ្តាល ស្តីអំពីសិទ្ធិមនុស្ស) រដ្ឋាភិបាលវៀតណាមចោទប្រកាន់មូលនិធីម៉ុងតាញ៉ា ដោយគ្មានភស្តុតាងតាមហេតុផលពិតឡើយ ដែលថាមូលនិធិម៉ុងតាញ៉ាជាក្រុមភេរវកម្ម ហើយចំពោះហេតុផលទាំងអស់នេះវិញ គឺមានបំណងហាមប្រាមរារាំងមិនឲ្យគណបក្ស TRP សហការនឹងអង្គការសហប្រជាជាតិ ។ របាយការណ៍នេះនឹងត្រូវគេធ្វើឲ្យអន្តរាយយ៉ាងសោកសៅក្នុងអង្គការសហប្រជាជាតិ ប្រសិនបើការចោទប្រកាន់ដោយឃោរឃៅបែបនេះ ត្រូវទទួលយកដោយគ្មានការពិនិត្យពិច័យម៉ត់ចត់ណាមួយ ដែលស្របនឹងស្តង់ដានៃការវិនិច្ឆ័យយុត្តិធម៌ និងសិទ្ធិការពារខ្លួនរបស់អន្តរជាតិនោះទេ ។

-សូមម្ចាស់ផ្តល់ជំនួយអន្តរជាតិ ទាំងបណ្តារដ្ឋាភិបាល និងអង្គការអន្តរជាតិ មេត្តាជួយពិនិត្យឲ្យបានម៉ត់ចត់នូវជំនួយទាំងឡាយដែលបានផ្តល់ឲ្យវៀតណាម និងសូមឲ្យអង្គការសហប្រជាជាតិធានាថាវៀតណាមត្រូវបញ្ឈប់អំពើហឹង្សារំលោភសិទ្ធិមនុស្ស និងរាល់ជំនឿសាសនា ដែលមានក្នុងប្រទេសវៀតណាម (តាមសេចក្តីរាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Right Watch) បានរាយការណ៍កាលពីថ្ងៃទី ០២ ធ្នូ ២០០៣ ស្តីពីវៀតណាមបានទទួលអំណោយ ) ៕

# សុន្ទរកថារបស់លោក ថាច់ តាន់តារា អតីតអធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោម

*ថ្លែងក្នុងឱកាសបុណ្យនាថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៥ នៅទីក្រុងឡង់ប៊ិច រដ្ឋកាលីហ្វក់ញ៉ា*

***PO Box 10, Huffman, TX 773446-0010 USA email: worldkk@earthlink.net No: 3/KKF/SC***

*លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី !*



*លោក ថាច់ តាន់ តារា អតីតអធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោម*

ខ្ញុំមានការសោកស្តាយជាអតិបរមា ដោយមិនបានមកចូលរួមក្នុងពិធីបុណ្យដ៏ឱឡារឹកនារាត្រីនេះ តាមសេចក្តីអញ្ជើញរបស់លោកអធិបតីសហព័ន្ធ ។ ខ្ញុំបានប្តូរថ្ងៃចូលមន្ទីរពេទ្យដែរ តែមិនបានសម្រេចដូចបំណង ហើយការចង់ថតជាវីដេអូក៏ធ្វើមិនកើតទៀត ព្រោះខ្ញុំចេញចូលមន្ទីរពេទ្យសឹងរាល់ថ្ងៃនៅឡើយ ។ ក្រោយពីការវះកាត់ ខ្ញុំសង្ឃឹមថា អវត្តមានរបស់ខ្ញុំនឹងមិនមានការរំខានអ្វីធំដុំដល់កម្មវិធីនារាត្រីនេះទេ ព្រោះខ្ញុំបានជូនដំណឹងនេះទៅលោកអធិបតីសហព័ន្ធតាំងពីពីរ ឬបីអាទិត្យមុនម្ល៉េះ ។ តែទោះជាយ៉ាងណាក្តីខ្ញុំក៏សូមថ្លែងអំណរគុណដល់សហព័ន្ធទាំងមូល និងដោយឡែកដល់គណៈកម្មការរៀបចំកម្ម–វិធីនេះ ដោយមានបំណងល្អចង់ផ្តល់កិត្តិយសដល់ខ្ញុំ ដែលបានបម្រើសង្គមខ្មែរក្រោមអស់ជាង ២០ ឆ្នាំកន្លងទៅ ។

បើក្រឡេកមើលទៅក្រោយ ឃើញថាខ្មែរក្រោមយើងបានបោះជំហានមួយយ៉ាងវែង ក្នុងការស្វែងរកអត្តសញ្ញាណជាតិរបស់ខ្លួន ។ ៣០ ឆ្នាំមុននេះ យើងត្រូវយួនមាក់ងាយធ្វើបាប កាប់សម្លាប់តាមទំនើងចិត្ត ហើយក៏មិនមានជាតិណា ដឹង ឬស្គាល់យើងផងដែរ ។ តែពេលនេះយើងមានមោទនភាពគ្រប់ ៗ គ្នា ព្រមទាំងឆ្ងើងឆ្ងៃថា បានកើតមកជាខ្មែរក្រោមទៀតផង ! នៅប្រទេសបារាំង ២៦ ឆ្នាំមុន ខ្ញុំប្រមែប្រមូលកម្លាំងជាតិបានគ្នាតែ ៤–៥ នាក់ប៉ុណ្ណោះ ។ យើងចាប់ផ្តើមធ្វើពីដៃទទេរហូតដល់មានសមាគមមហាសន្និបាតសកល សហ–ព័ន្ធ និងវត្តអារាមនៅពាសពេញលើផែនដី ដែលនៅក្រោមការដឹកនាំតែមួយ ។ ពេលនេះខ្មែរក្រោមមានទង់ជាតិ ភ្លេងជាតិ វិទ្យុផ្សាយសំ–ឡេង គេហទំព័រលើអ៊ីនធឺណែត ព្រមទាំងបានចូលជាសមាជិក នៃអង្គការអន្តរជាតិនានា មានអង្គការយូអិនភីអូ សហព័ន្ធទូកងអន្តរជាតិ និងក្រុមជំនុំអចិន្ត្រៃយ៍នៃជនជាតិដើមរបស់អង្គការសហប្រជាជាតិ ជាដើម ។ ឥឡូវនេះ ការចូលធ្វើជាសមាជិកនៃអង្គការព្រះពុទ្ធសាស–នាពិភពលោក ក៏ជិតបានក្លាយទៅជាការពិតផងដែរ ។ ដូច្នេះស្ថាប័នចាំបាច់ ដែលជាឧបករណ៍សម្រាប់ការតស៊ូរបស់ជាតិយើង ខ្ញុំបានណែនាំបង្កើតឡើងសព្វគ្រប់អស់ហើយ នៅសល់តែការស្មោះត្រង់នឹងគ្នា ចេះសាមគ្គីគ្នា និងចេះចាត់ការឲ្យបានសមស្របប៉ុណ្ណោះទៀតយើង នឹងបានទទួលជោគជ័យជាបន្តបន្ទាប់ជាមិនខាន ។ ធម្មជាតិជាអ្នកបង្កបង្កើត ខ្ញុំតែងតែសប្បាយរីករាយ និងមានមោទភាពជាងអ្នកណា ៗ ទាំងអស់ នៅគ្រប់ពេលដែលខ្ញុំបានឃើញផ្លែផ្កាចេញមកពីការបរិច្ចាគដ៏ស្មោះស្ម័គ្របំផុតរបស់ខ្លួននោះ ។ ទោះជាបានដឹងថា "អ្នកឡើងមិនបានបេះ អ្នកប្រលេះមិនបានឆី..." ដូចពាក្យចាស់លោកតែងតែពោលក៏ដោយ បុព្វការីជនយើង ក៏ដូចរូបខ្ញុំដែរ មិនដែលរុញរាក្នុងការកាប់ឆ្ការ វែកផ្លូវទុកឲ្យអ្នកក្រោយឡើយ ! ជាការប្រសើរណាស់ដែលពេលនេះ អស់លោក–លោកស្រី នាំគ្នាធ្វើពិធីដឹងគុណដល់អ្នកដើរមុន ព្រោះនេះជាលំនាំមួយដ៏ល្អសម្រាប់អ្នកជំនាន់ក្រោយត្រាប់តាមផងដែរ ។ ហើយនេះក៏ជាវប្បធម៌ដ៏ប្រពៃមួយទៀត ដែលយើងត្រូវមានដូចលោកអធិបតីសហព័ន្ធ តោគឹមថុង បានប្រាប់ខ្ញុំថា ចង់បង្កើតឲ្យមានតាំងពីពេលនេះតទៅ តែដោយខ្ញុំយល់ថា សហព័ន្ធជាទីកន្លែងសម្រាប់យើងរកកិត្តិយសជូនជាតិ មិនមែនជាកន្លែងសម្រាប់ឯកជនណាម្នាក់ យកទៅប្រើដើម្បីរកកិត្តិយសផ្ទាល់ខ្លួននោះទេ ។ ដូច្នេះបើខ្ញុំមានកិត្តិយសពេលនេះ គឺជាកិត្តិយសរួមនៃអ្នកបម្រើការងារក្នុងសហព័ន្ធទាំងអស់គ្នា មិនមែនជារបស់ខ្ញុំម្នាក់ឯងឡើយ ។ ម្ល៉ោះហើយខ្ញុំសូមចែកជូនកិត្តិយសនេះ ទៅសមាជិក–សមាជិកាសហព័ន្ធទាំងអស់វិញ ជាពិសេសសហការីរបស់ខ្ញុំទាំងអស់ ដែលបានគាំទ្រខ្ញុំ

ក្នុងរយៈកាល ជាង ២០ ឆ្នាំកន្លងទៅនេះ ។ បើមិនមានការគាំទ្រវឹងមាំនេះទេ ពិតជាមិនមានរាត្រីសមោសរនេះឡើយ ។ ខ្ញុំសូមអរគុណដ៏ជ្រាលជ្រៅចំពោះវិភាគទានដ៏ប្រសើរនេះ ដែលញ៉ាំងឲ្យខ្ញុំមានលទ្ធភាពអាចជួយខ្មែរក្រោមបាន ។

ដូចសមាជិក-សមាជិកាយើងបានជ្រាបហើយថា បេសកកម្មរបស់យើងជាខ្មែរក្រោមនៅបរទេស ក្នុងការជួយទាមទារ "សិទ្ធិដោះស្រាយវាសនាខ្លួនដោយខ្លួនឯង" ជូនដល់ខ្មែរក្រោមនៅក្នុងស្រុកនោះ មិនទាន់ជ្រួតជ្រាបដល់គ្រប់អង្គការរដ្ឋលើសកលោកនៅឡើយទេ ។ ទោះជារដ្ឋអំណាចយួន បានដឹងច្បាស់ថា ខ្មែរក្រោមយើងចង់បានអ្វីហើយក៏ដោយ សហព័ន្ធក៏ត្រូវបន្តការទាមទារនោះ តទៅទៀតតាមរយៈអង្គការយូអិនភីអូដដែល ។ ដូចខ្ញុំបានជម្រាបច្រើនដងមកហើយថា យើងបានដាក់ក្នុងលិខិតទាមទារតម្រូវឲ្យយួនដោះស្រាយដែលសហព័ន្ធមិនត្រូវផ្លាស់ប្តូរទេនោះ គឺ ៖

ប្រការ ១ ៖ រដ្ឋអំណាចយួនត្រូវឈប់ធ្វើអាណានិគមលើដែនដីកម្ពុជាក្រោម ។

ប្រការ ២ ៖ រដ្ឋអំណាចយួនត្រូវដាក់កម្ពុជាក្រោមឲ្យនៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ ដែលអាចផ្តល់សិទ្ធិសេរីភាពគ្រប់គ្រាន់ ដល់ខ្មែរក្រោមក្នុងការជ្រើសរើសសិទ្ធិដោះស្រាយវាសនារបស់ខ្លួន ។

បន្ថែមពីលើនេះ ការឡោមព័ទ្ធរដ្ឋអំណាចយួន ខាងផ្លូវសេដ្ឋកិច្ច ផ្លូវទូត ផ្លូវនយោបាយ និងសិទ្ធិនានា ដែលយើងជាម្ចាស់ស្រុកត្រូវទទួលបាន និងធ្វើឲ្យរដ្ឋអំណាចយួនសុខចិត្តពិនិត្យដល់ការទាមទាររបស់ខ្មែរក្រោមមិនខាន ។

ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមផ្ញើនូវសេចក្តីសរសើរយ៉ាងកក់ក្តៅបំផុតដល់ជោគជ័យថ្មី ដែលគណៈប្រតិភូនានា របស់សហព័ន្ធ ដែលទើបតែទទួលបាននោះ គឺគណៈប្រតិភូទៅជួបជាមួយក្រសួងការបរទេសនៃសហរដ្ឋអាមេរិក គណៈប្រតិភូទៅចូលរួមការប្រណាំងទូកងនៅប្រទេសកម្ពុជា គណៈប្រតិភូទៅប្រជុំជាមួយអង្គការយូអិនភីអូ នៅក្រុងឡាអេ ដែលទើបតែបានចូលជាសមាជិកអចិន្ត្រៃយ៍របស់អង្គការនេះផងនោះ និងគណៈប្រតិភូព្រះសង្ឃខ្មែរក្រោម ដែលទៅចូលរួមមហាសន្និបាតព្រះពុទ្ធសាសនាពិភពលោក នៅប្រទេសភូមា ។ ជោគជ័យទាំងនេះនឹងប្រមូលផ្តុំទៅជាជោគជ័យធំមួយ របស់ជាតិខ្មែរក្រោមទាំងមូលនៅថ្ងៃដ៏ខ្លីខាងមុខមិនខាន ។ ខ្ញុំក៏សូមអរគុណដល់លោកអធិបតីសហព័ន្ធ ដែលបានធ្វើសេចក្តីរាយការណ៍ពីសកម្មភាពទាំងនេះមកខ្ញុំផងដែរ ។

ចំពោះផ្ទាល់ខ្លួនខ្ញុំវិញ ដូចបានជម្រាបជូនអង្គមហាសន្និបាតសកលលោកលើកទី ៧ នៅរដ្ឋញូវជើស៊ី ហើយថាខ្ញុំនឹងវិលត្រឡប់មកដឹកនាំសមាគមខ្មែរកម្ពុជាក្រោមសហរដ្ឋអាមេរិកវិញក្នុងនាម ជាអធិបតី និងជាប្រធានរបស់អង្គការនេះ ។ សមាគមខ្មែរកម្ពុជាក្រោម-សហរដ្ឋអាមេរិក គឺជាអង្គការបង្កើតនឹងទ្រង់ទ្រាយសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលខ្ញុំបានណែនាំបង្កើតពីឆ្នាំ ១៩៨២ ហើយបានច្បាប់រដ្ឋឲ្យធ្វើសកម្មភាពជាផ្លូវការតាំងពីឆ្នាំ ១៩៨៤ មកម្ល៉េះ ។ នៅពេលនេះដោយខ្ញុំយល់ឃើញថា ខ្មែរក្រោមនៅបរទេសទាំងអស់ បានធ្វើសកម្មភាពស្នេហាជាតិជាច្រើន ជាពិសេសគឺសហព័ន្ធនេះតែម្តងតែមិនទាន់មានកន្លែងតម្កល់ទុកឯកសារ នៃសកម្មភាពទាំងនេះនៅឡើយទេ ។ ហើយបើមិនប្រមែប្រមូលទាន់ពេលវេលាទេ ឯកសារ ឬស្នាដៃទាំងនោះនឹងត្រូវបាត់បង់ទាំងអស់មិនខាន ។ ម្ល៉ោះហើយ ជាការចាំបាច់ណាស់ ដែលយើងត្រូវកសាង "សារមន្ទីរជាតិ" មួយនៅពេលនេះ ។ គណៈកម្មការនាយកនៃសមាគមខ្មែរក្រោម សហរដ្ឋអាមេរិក បានសម្រេចកសាងសារមន្ទីរជាតិនេះ នៅក្នុងបរិវេណវត្តកម្ពុជាក្រោមនៅក្បែររដ្ឋធានីវ៉ាស៊ីនតោន ។ វត្តកម្ពុជាក្រោមនេះមានដីទំហំជាង ៥ អេកកើ នៅក្រោមច្បាប់របស់សមាគមខ្មែរកម្ពុជាក្រោម សហរដ្ឋ-អាមេរិក ដែលមានព្រះតេជគុន ថាច់ សួន ជាចៅអធិការ ។ បុណ្យផ្កាសម្រាប់រកបច្ច័យកសាងសារមន្ទីរជាតិនេះនឹងធ្វើឡើងនៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០០៥ ។ លិខិតបវារណាបុណ្យផ្កានឹងផ្ញើជូននៅពេលក្រោយ ។

ក្រៅពីនេះ ក្នុងនាមជាជនជាតិអាមេរិកកាំង និងក្នុងនាមជាអ្នកដឹកនាំកងទ័ពខ្មែរក្រោមម្នាក់ ក្នុងសង្គ្រាមវៀតណាម ខ្ញុំនឹងសុំឲ្យរដ្ឋសភាសហរដ្ឋអាមេរិកចេញច្បាប់មួយទទួលស្គាល់ការបរិច្ចាគ ដ៏ធំធេងរបស់ខ្មែរក្រោមក្នុងសង្គ្រាមនោះ ដូចជនជាតិ ម៉ុង លាវ វៀតណាមដែរ ។ ខ្ញុំយល់ថាច្បាប់នេះនឹងទុកដូចជាបញ្ជីជាតិរបស់ប្រទេសកម្ពុជាក្រោម ដែលយើងទាំងអស់គ្នាអាចយកទៅប្រើប្រាស់នៅគ្រប់ទិសទី នៅគ្រប់ពេលដែលយើងត្រូវការស្វែងរកប្រយោជន៍ឲ្យខ្មែរក្រោម ។ បន្ទាប់ពីបានច្បាប់នេះខ្ញុំនឹងសុំសង់ចេតិយមួយនៅរដ្ឋធានីវ៉ាស៊ីនតោនទៀត ដើម្បីធ្វើជាបូជនីយដ្ឋានជូនដល់អ្នក ដែលបានបូជាជីវិតនៅមាតុប្រទេសកម្ពុជាក្រោមយើង ព្រោះសិទ្ធិ ប្រជាធិបតេយ្យ និងសេរីភាព ។

ដូច្នេះខ្ញុំសូមអំពាវនាវដល់ខ្មែរ-ខ្មែរក្រោមគ្រប់រូបដែលបានឃើញផលប្រយោជន៍ច្បាស់ពីកិច្ចការជាតិទាំងពីរនេះ សូមចូលមកជួយឧបត្ថម្ភតាមកម្លាំងសទ្ធាគ្រប់ ៗ គ្នា ។ ខ្ញុំសូមអរគុណទុកជាមុន ។ (សូមទាក់ទងតាមអសយដ្ឋានរបស់សមាគមខាងលើ) ។

នៅទីបញ្ចប់ខ្ញុំសូមជូនពរដល់ថ្នាក់ដឹកនាំសហព័ន្ធ អាណត្តិកាលថ្មី ២០០៤-២០០៧ និងសមាជិក-សមាជិកា សហព័ន្ធទាំងអស់ឲ្យបានប្រកបនូវពុទ្ធពរទាំងប្រាំប្រការ ក្នុងឱកាសចូលឆ្នាំថ្មី ២០០៥ នេះកុំបីខាន ។ ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមស្នើឲ្យសហព័ន្ធរកថវិកាសង្គ្រោះខ្លះទៅជួយដល់ជនរងគ្រោះនៅអាស៊ី ដោយសារការរញ្ជួយដែនដី ដែលទើបតែកន្លងមួយអាទិត្យមុននេះផងតាមការគួរ ។ ទង្វើនេះអាចបញ្ជាក់ជាថ្មីម្តងទៀត ដល់អង្គការអន្តរជាតិនានាអំពី "នយោបាយថ្លៃថ្នូរ" របស់សហព័ន្ធខ្មែរកម្ពុជាក្រោមផងដែរ ។

ដោយចិត្តស្រឡាញ់ខ្មែរក្រោម និងដែនដីកម្ពុជាក្រោមដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ ។

**សូមអរគុណ !**

# រឿងកំពប់តែអុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ

១-ទុស្សករកុលិយេ  សិរោមេឱនអង្គអញ
ភិវាទកោរុព្ភ  ពុទ្ធបាទកបកងច័ក្ខ ។
២-ព្រះបាទព្រះរាជភូវ  កើតកបត្រូវព្រះលាយល័ក្ខ
មួយរយប្រាំបីជាក់  ជាពុំនាក់ភព្វបីបាន ។
៣-បង្គមគុនព្រះធម្ម  តូដសូពាណាភេត្រាយាន
នាំសតសង្សាបាន  ត្រង់ត្រើយត្រានឥតអំពល់ ។
៤-បង្គមគុនព្រះសង្ឃ  សីលសឹងទ្រង់ករុណាសល់
ជាស្រូវស្រែបុណ្យផល  នាមតាកដល់ថ្នល់សុក្ខា ។
៥-ហេតុនោះអង្គអញខ្ញុំ  ក្រាបបង្គំគុនរតណា
សូមសុកសូមទីឃា  យុឃឹនយូរយស្សវេងឆ្ងាយ ។
៦-ដេជៈអង្គអញខ្ញុំក្រាប  បង្គំបង្កេចក្យ
សូមសុកសូមសប្បាយ  ដោយតេជព្រះរតណា ។
៧-បពិតរីសំណូម  នោះខ្ញុំសូមសុំសបាទ
សូមធុតចំហុតប្រាកដ្ឋ  រៀងរួចដល់និព្វាន្ត ។
៨-ជាតិនេះខ្ញុំអាភ័ព្វ  ឥតគេរាប់កំណើតប្រាន
ជាតិក្រោយឲ្យខ្ញុំបាន  ទាន់ព្រះអង្គគុងធម្មា ។
៩-សូមទេពទាំងទិសទស  សួរសោឡសសោយសុក្ខា
រួចរាល់រាល់ព្រម្មា  សូមជួយជាញាណសក្ខីយ ។
១០-ឆ្នាំកុរសបស័ក្ខ  ហេមន្តជៀងជាក់
ចូល១០រោជ ឱ្មីយ  ព្រហស្បត៍ឧតម្ត
សានសំរិទ្ធិ  ខែបុស្សពិតពៃយ
ឡើងប្រាងហើយណា ។
១១-សករាជ្យគ្រប់គ្រាន់  កន្លងពីរពាន់
បួនរយគនា  ប្រាំបីដណ្តាប់
ឆ្នាំគ្រប់វស្សារ  ខែប្រាំបីជា  ៩ថ្ងៃផ្លាយ ។
១២-អបំនាម្មោ  ចន្ទសរោ
ត្រូវគ្រប់ទាំងឡាយ  គន់គិតគ្រប់គ្រង
សង្ឃផងខ្វល់ខ្វាយ  បរដៅសម្ពាយ  ជាធំធិបតី ។
១៣-គុងវព្យចុងកោះ  ប្រាកមានបិតនោះ



ស្មោះពិតព្រះទ័យ  ចម្លងសោវតា
លោកតានាមនៃ  បុទុមបរមី
ដើមឈ្មោពេជ្ញា ។
១៤-រីឯអង្គអញ  យល់ស្រុកខ្មែរមិញ
មិនសូវសុក្ខា  តែងកើតទោសទុក្ខ
អាក្រក់គ្រុបគ្រា  ក្រុងកម្ពុជា
នោះនឹងស្វាត់បាត់ ។
១៥-ហេតុនេះអង្គអញ  សូមសំដែងចេញ
ជាកិរទៀតទាត់  សូមថ្វាយព្រះពរ
បរវរនូវរត្ន  សូមព្រះនាមក្សត្រ
ជាម្ចាស់សិរិសារ ។
១៦-សំដែងទុកទៅ  ឲ្យអស់កូនចៅ
ដឹងដើមដូនតា  កាលពីព្រេងព្រឹទ្ធ
បាត់ស្វាត់យូរយារ  ទុកជាមាត្រា
រហូរអស់ក្សត្រ ។
១៧-ពាក្យពិតសភាព  បពិត្រពោលរាប់
ក្រែងភ្លាំងភ្លេចភ្លាត់  ពិតពុំទាក់ទង
ទំនងមហាក្សត្រ  អ្នកណាចាំស្ទាត់
តម្រង់ឲ្យទាន ។
១៨-ទុកជាកេរ្តិ  ក្រោយគ្រាន់ចំណោរ

តទៅមុកមាន កុំឲ្យសូនស្ងាត់
បង់បាត់បុរាណ ទុកជានិទាន
រឿងក្សត្រផង ។

១៩-ដ្បិតកាលពីមុន មហាក្សត្រមានបុណ្យ
ស្តេចគុងគ្រប់គ្រង បន្ទាយឧដុង្គ
មានដៃយនោះហោង តំណែលតម្កង
តំណាក់ទាំងឡាយ ។

២០-កាលស្តេចកុមារ ព្រះវរមាតា
បិតាច្បងច្បាស់ មានព្រះឱង្ការ
រក្សាត្រង់ត្រាស់ ព្រះនាមបុត្រច្បាស់
ឲ្យហៅអង្គតន់ ។

២១-ស្តេចឲ្យមេនំ ពីល្បែងច្រៀងបំ
ពេពិតពីក្មេង លុះពេញរូបអង្គ
ទើសទ្រង់នោមផ្សឹង ព្រះបិតាឯង
ឲ្យបុត្តបន្តូល ។

២២-គ្រប់គ្រងរាជា ព្រះដៃជេត្ថា
រាម្មាឥសូរ គ្រប់គ្រងសម្បត្តិ
ជាតិជាកំពូល រាជរដ្ឋអនុកូល
រាជជាបូរី ។

២៣-ស្តែងស្តេចទ្រង់ធម៌ ប្រសើរឥសូរ
រុងរឿងនាម្ចីយ ថ្កុំថ្កើងសាន្តសុក
អស់មុខមន្ត្រី សេណាបុតី
រុងនាសម្តព ។

២៤-នៅអស់បរោហិត ករីបន្ទិត
ព្រាហ្មពឹទ្ធប្រាជ្ញប្រាយ ស្នេហស្និទ្ធិជាទំ
ឆ្អញជមសព្វសាយ រាស្ត្រផងទាំងឡាយ
មិនមានហ្មងសៅ ។

២៥-ព្រះដៃជេស្ថា ស្តេចមានបុត្រា
ជាច្បងនៃបនៅ ព្រះវរបិតា
មាតាស្នួនពៅ សន្មតនាមហៅ
អង្គចន្ទកុមារា ។

២៦-ព្រះរាជបុត្រច្បង កាលកើតនោះហោង
ព្រះពុទ្ធសាសនា កន្លងពីពាន់
បីរយគនា និង១០វស្សា
ប្លាយសៃសឆ្នាំបូន ។

២៧-ឯបុត្តបន្ទាប់ ព្រះនាមស្រេចស្រាប់
ឲ្យហៅអង្គស្ងួន អង្គអឹមអង្គដួង
គ្រប់លួងទាំងបួន បិតាថៃរថួន
ស្ងួនគ្រប់បេត្តី ។

២៨-ទើបអង្គអាត្មា គុណគិតកាព្យា
សរសើរសេចក្តី ពិតពីព្រះបាទ
ននាដ្ឋចក្រី ឥសូរសិរសី
ទ្រង់រាជថ្កើងថ្កាន ។

២៩-លុះស្តេចរាជា សោយព្រះវិសា
ល្បែលុះចាកស្ថាន ឥស្សារាស្ត្ររល់
អំពល់ព្រួយប្រាណ ពុំសូវសុកសាន្ត
ក្នុងរាជពិភព ។

៣០-ដ្បិតលោកចៅហ្វា ប៉ុកពិតជាតិជា
បិតាធម៌ថប តាក់តែងមន្ត្រី
សេនីសាយសព្វ សង់មេនមានថ្កប់
ក្សួរក្សាច់រចនា ។

៣១-ធ្វើបុណ្យសព្វថ្ងៃ ទុកព្រះសពថ្ងៃ
ពេញពីរវស្សារ ឲ្យទានទ្រព្យធុន
ធ្វើបុណ្យមហិមា ទើបបានបូជា
ថ្វាយព្រះអាគ្គី ។

៣២-ហើយលោកគុនគិត ឲ្យតែងអស់ឥដ្ឋ
ក៏ជាចេតី បញ្ចុះព្រះធាតុ ព្រះបាទចក្រី
ធ្វើបុណ្យប្រក្រតី អធិថ្វាយទៅ ។

៣៣-លោករួមរក្សា ព្រះរាជបុត្រា
ទាំងបួនចោមចៅ គ្រប់គ្រងធានី
បូរីឥតសៅ អស់រាស្ត្រក្នុងក្រៅ
សឹកសុកសប្បាយ ។

៣៤-លុះយូរបន្តិច បុត្រ៤អង្គស្តេច
ចំរើនរូបកាយ ពាលពេញព្រះអង្គ
ទើសទ្រង់នោមឆាយ នាំលួងទៅថ្វាយ
សម្តេចពុទ្ធិចៅ ។

៣៥-រីឯចៅហ្វាយ ប៉ុកពុំយូរយារ
អញ្ជើញស្តេចទៅ ឲ្យរៀបជើងទឹក
ពន្លឹកក្រែក្រៅ ពលពាលខ្វលខ្មៅ
ដង្ហែស្តេចស្តែង ។

៣៦-ចរចុះជើងទឹក    ទីយនាំងភ្លើភ្លឹក
  រន្ទាលទិព្វទែន    ឲ្យគោះដំស្គរ
  ទូងទរគគ្រែង    ដេញដំផ្លុំភ្លេង
  សូរសព្ទរងំ ។
៣៧-លុះបានពេលា    លាក្ខឫក្សជោគជា
  ប្រពៃឧត្តម    តាំងហោចរចេញ
  បាញ់កាំភ្លើងធំ    ទុម្ពេងភ្លេងភ្លំ    រងំចេញទៅ ។
៣៨-អស់រាស្ត្រទាំងឡាយ    ស្រើបស្រាលសប្បាយ
  បទបុគ្គចោមចៅ    ចរចេញហែរស្តេច
  ត្រង់ត្រេចសំដៅ    តម្រង់ឆ្ពោះទៅ ត្រូវបាត់ដំបង ។
៣៩-ឯអង្គអព្ភៃ    ត្បែសបែននោះនៃ
  អរក្រៃកន្លង    ហេតុត្រូវគំនិត
  គុនគិតប៉ុនប៉ង    និងថ្វាយកូនផង
  ជាតិជាសំរាប់ ។
៤០-គិតស្រេចពុំលង់    លោកក៏រៀបសង់
  បន្លាជាឆាប់    ជិតជើងកំពង់
  ប្រៀបប្រុងប្រដាប់    គ្រប់គ្រងសំរាប់
  ឥតឯខ្វះឡើយ ។
៤១-សម្តេចចៅហ្វា    ល្អួង៤អង្គារ
  ចូលរាបចាត់ហើយ    ពិតពុំយូរយារ
  លេលាត្រង់តើយ    ព្រះពន្លាហើយ
  ស្តេចឡើងទៅគង់ ។
៤២-អព្ភៃត្បែសស្រួល    រករៀបទទួល
  ទាំង៤ព្រះអង្គ    សំរាលអាស្នារ
  អាហារផ្ចិតផ្ចង់    ថ្វាយទាំង៤អង្គ
  ឲ្យសោយសោះឃ្លាន ។
៤៣-ស្រេចហើយអព្ភៃ    ត្បែសបែននោះនៃ
  គុនគិតពិធ្យាន    ចង់ថ្វាយបុត្រី
  ប្រឹមប្រិយកល្យាណ    ឃាត់ស្តេចឲ្យខាន
  កំសាន្តព្រះទ័យ ។
៤៤-ទាំងលោកចៅហ្វា    ប៉ុកពិតពុំជា
  ម្តេចៗឡើយនៃ    ព្រមឲ្យល្អួងខាន
  កំសាន្តព្រះទ័យ    នៅនេះយូរថ្ងៃ
  ឯម្ចាស់អង្គច័ន្ទ ។
៤៥-ឃើញកូនអព្ភៃ    ត្បែសបែននោះនៃ
  ព្រះទ័យខ្មាន់ខ្មាញ់    គិតកើតស្នេហា
  ចិន្តាក្ងួចកាន    រករិះដិះដាន
  ជាទេពីពិត ។
៤៦-អព្ភៃត្បែសបាន    ដឹងដោយដើមដាន
  ព្រះទ័យស្តេចគិត    ចង់បានបុត្រី
  តូចក្តីគំនិត    អព្ភៃត្បែសគិត
  ចូលទូលស្តេចថា ។
៤៧-បពិត្តបើស្តេច    សព្វព្រះទ័យស្រេច
  កូនខ្ញុំករុណា    នឹងថ្វាយស្តេចបាន
  តូចភ្នានចិន្តារ    កុំព្រួយព្រះហារ
  ទៃគិតត្រង់ណោះ ។
៤៨-សូមតែស្តេចទៅ    បង្គំព្រះចៅ
  ដូចដោយចំពោះ    បើស្តេចស្តែងបាន
  វិលថ្កានមកស្មោះ    ខ្ញុំថ្វាយកាលនោះ
  តាមសព្វព្រះទ័យ ។
៤៩-ស្តេចស្តាប់ពើសព្រហ្ម    ព្រះទ័យល្មាក់ល្មម
  តាមពាក្យអព្ភៃ    ត្បែសសោតរៀបខ្លួន
  ជូនហែក្សត្រថ្លៃ    ដល់ដូចព្រះទ័យ
  នៃស្តេចកាលនោះ ។
៥០-ដល់ហើយចូលថ្វាយ បង្គំគរកាយ
  ទូលទៅសព្វសុះ    ព្រះចៅយុធ្យា
  ករុណាស្មើស្មោះ    អព្ភៃត្បែសនោះ
  ឲ្យវិលវឹងវិញ ។
៥១-ឯលោកចៅហ្វារ    ប៉ុកពុំឃ្លាតឃ្លា
  រក្សាស្តេចមិញ    ត្បិតនៅកុមារ
  មិនទាន់ឲ្យចេញ    មកស្រុកខ្មែរវិញ
  ត្បិតក្មេងនៅឡើយ ។
៥២-ចៅហ្វាប៉ុកនៅ    ល្អួងប្អូនព្រះចៅ
  ឃាត់នៅនោះហើយ    ពុំបាននិយាយ
  ថែងចាយទៀតឡើយ ទុកស្នេះសិនហើយ
  ទិម្មនោះនឹងនៅ ។
៥៣-បទពុំនោលនិទានទៅ    សំដីសំដៅ
  សម្តែងឯស្រុកខ្មែរវិញ ។
៥៤-កាលក្រោយចៅហ្វាប៉ុកចេញ
  ទៅសៀមនោះមិញ    មិនសូវសុកសានសប្បាយ ។

៥៥-អស់រាស្ត្ររកស៊ីសព្វសាយ ចេញចូលជួញចាយ
ខ្វល់ខ្វាយរិះរកទ្រព្យធន់ ។
៥៦-មានចោរកាចកិច្ចប្លមប្លន់ យកអស់ទ្រព្យធន់
បញ្ឆោតបញ្ឆកលុកកាប់ ។
៥៧-បើពុំព្រមឲ្យអស់ទ្រព្យ ទៅវាវាកាប់
យកទ្រព្យអស់ឥតសំម្ចៃ ។
៥៨-សព្វស្រុកពុំសុកឡើយនៃ គ្រប់ខែត្តទីទៃ
តែងធ្វើអំពើរនោះហោង ។
៥៩-ឮលេចពាក្យពេចន៍អ្នកផង ស្រដីអឺងកង
ដល់បាត់ដំបងនោះនៃ ។
៦០-កាលនោះឯអង្គអព្តៃ ត្បែសបែននោះនៃ
វៃយដឹងដោយឈ្មួញជួងប្រែ ។
៦១-ថាកើតកង្វល់ស្រុកខ្មែរ រាស្ត្ររកជួញប្រែ
សឹងតែពុំបានគ្រប់ច្រក ។
៦២-អព្តៃត្បែសបែន រិះរកធ្វើសំបុត្រមក
ប្ដឹងទៅចៅហ្វាវិញថា ។
៦៣-ឲ្យគិតគំនិតប្រាជ្ញា យកសេចក្ដីនោះណា
សំគួរក្រាបទូលព្រះចៅ ។
៦៤-តាមដោយសំបុត្រប្ដឹងទៅ ចៅហ្វារប៉ុកនៅ
នាយចូលទូលតាមសេចក្ដី ។
៦៥-សម្ដេចពុទ្ធិចៅចក្រី បានជ្រាបសេចក្ដី
ទើបមានមេត្រីត្រាស់ថា ។
៦៦-នឹងឃ្យចៅឯអង្គារ សម្ដេចចៅហ្វារ
វិលទៅឯស្រុកខ្មែរវិញ ។
៦៧-ដ្បិតក្មេងកុមារនោះមិញ បើច្នេះអង្គអញ
ឲ្យអព្តៃយត្បែសបែនទៅ ។
៦៨-គិតស្រេចសម្ដេចពុទ្ធិចៅ តាងបន្ទូលទៅ
ឲ្យអង្គអព្តៃយត្បែសឯង ។
៦៩-គ្រងជាចៅហ្វាយរតាក់តែង ចេញចាប់ចោរលេង
ឯស្រុកខ្មែរឯងឲ្យបាន ។
៧០-អព្តៃត្បែសដឹងដើមដាន ស្ដេចត្រាស់ប្រើប្រែ
ពុំហ៊ានបង្អង់លង់ឡើយ ។
៧១-គិតចេញមកស្រុកខ្មែរហើយ ពិតពុំយូរឡើយ
ឲ្យហៅនាហ្មឺនតូចធំ ។
៧២-ស្រុកខ្មែរមកដល់ជួបជុំ គុនគិតជំនុំ
សួរអំពីពុតពាលនោះ ។
៧៣-នាហ្មឺនខ្មែរប្ដឹងសព្វសុះ គ្រប់ខែត្តទាំងនោះ
ឥតឯចន្លោះខ្វះឡើយ ។
៧៤-អព្តៃត្បែសបានដឹងហើយ គិតពុំឆ្ងល់ឡើយ
លោកយល់យកនឹងប្រាជ្ញា ។
៧៥-លោកធ្វើអំពើរកិច្ចការ ហៅមនុស្សណាជា
ជឿចិត្តគំនិតប្រើប្រាប់ ។
៧៦-ប្រាឯងចូលទៅនៅផ្កាប់ មេចោរយកទ្រព្យ
តាមវាបង្គាប់គិតធ្វើ ។
៧៧-ចូលទៅជាបាវបំរើ តាមដោយអំពើ
វាធ្វើដូចម្ដេចធ្វើនោះ ។
៧៨-សង្ងំកុំឲ្យដឹងស្មោះ គំនិតវានោះ
ពិតហើយមកប្រាប់អង្គអញ ។
៧៩-នឹងគិតបំពត់វាវិញ ផ្ដាំស្រេចប្រើចេញ
ទៅនៅគ្រប់ខេត្តទាំងឡាយ ។
៨០-មេចោរខែត្តកំពង់ស្វាយ ឈ្មោះតេងឈ្មោះឡាយ
ជានាយនាំរាស្ត្រគិតប្លន់ ។
៨១-យករអស់របស់ទ្រព្យធន់ វានៅចាំប្លន់
នៅភ្នំយាយសួរនោះហោង ។
៨២-ចេញទៅទន្លេសាបផង មើលអស់ឈ្មួញឆ្លង
នឹងប្លន់យកទ្រព្យធន់នោះ ។
៨៣-អស់បំរើអព្តៃ ត្បែសបែនចូលដៃ
ដឹងដើមដំណើរសាយសព្វ ។
៨៤-ចូលទៅប្ដឹងលោកទាំងគ្រប់ លោកប្រើត្រឡប់
យកទ្រព្យទៅឲ្យអស់រាស្ត្រ ។
៨៥-សឹងតែខ្សែនព្រៃជា ជាជាតិទេសផ្កា
ឲ្យខំធ្វើការឲ្យបាន ។
៨៦-នឹងឲ្យរង្វាន់ធនធាន អស់មេគ្រប់ប្រាណ
ប៉ុន្មានមូលមកបានម្ដង ។
៨៧-អញបន្តឹងស្គាល់មុកផង មាសប្រាក់កែវកង
អញឲ្យដោយចិត្តប្រាថ្នា ។
៨៨-ទ្រព្យធនទាំងប៉ុនសក្ខតា បើបានធ្វើការ
បានហើយអញឲ្យទាំងគ្រប់ ។
៨៩-ផ្ដែផ្ដាំបំរើសារសព្វ នាំទ្រព្យត្រឡប់
ទៅឲ្យដោយមេគ្រុបគ្នា ។ (**នៅមានត**)




**បញ្ញាសជាតក**
រឿងទី ១២

*ជាស្នាដៃនិពន្ធរបស់លោក **ញ៉ុក ថែម***
*បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩*

# រឿងអាទិត្តរាជ

ក្នុងអតីតកាល មានព្រះរាជា ១ ព្រះអង្គ ព្រះនាមព្រះបាទអាទិត្តរាជគ្រងរាជ្យក្នុងជេតុត្តរនគរ ព្រះអគ្គមហេសីព្រះនាមព្រះនាង សង្ខទេវី ។ ព្រះរាជាទ្រង់ធមិមានព្រះទ័យសប្បុរសក្រៃលែង ទ្រង់បានឲ្យសង់សាលាធទាន គឺសាលា ៤ ខ្នង នៅទ្វារនគរទាំង ៤ មួយខ្នងនៅកណ្តាលនគរ មួយខ្នងទៀតនៅជិតទ្វារព្រះរាជវាំង ទ្រង់បានបំណាយព្រះរាជទ្រព្យដាក់ទានដល់ស្មូមយាចកអ្នកកំសត់ទុគិត ក្នុងមួយថ្ងៃមួយសែនកហាបណៈរាល់ ៗ ថ្ងៃ ។

រាត្រីមួយ ព្រះរាជាទ្រង់ព្រះសុបិនថា "មានព្រាហ្មណ៍ចាស់ជរាម្នាក់មកសូមភោជនព្រះអង្គ" ទ្រង់តើនឡើង ទ្រង់យល់ថា ព្រឹកនេះនឹងមានស្មូមយាចកសូមភោជនពុំខាន ។ ទ្រង់មានព្រះតម្រិះទៅទៀតថា "បើមានជនណាមួយមកសូមបេះដូងអញ ៗ នឹងពុះទ្រូងរូងយកសាច់បេះដូងដាក់ជាទាន បើសូមក្បាលនឹងកាត់ក្បាលដាក់ទាន ឬសូមសរីរៈទាំងមូលក្តី ក៏អញដាក់ទានឥតក្តីសោកស្តាយ ឬ តក់ស្លុតឡើយ ។ គ្រានោះស្រាប់តែកើតការណ៍អស្ចារ្យ មានប្រការផ្សេង ៗ មានផែនដីកម្រើកញាប់ញ័រជាដើម ។

ព្រះឥន្ទ្រាធិរាជ ទ្រង់បានជ្រាបសភាពព្រះហឫទ័យនៃព្រះបាទអាទិត្តរាជដូច្នោះហើយ ក៏ស្តេចចុះពីឋានទេវលោកមក ហើយទ្រង់បាននិម្មិតជាព្រាហ្មណ៍ចាស់ជរា ។ ដៃកាន់ឈើច្រត់ រាងកាយស្គាំងស្គម សក់ស្កូវ ដើររញីរញ័រចូលមករកព្រះអង្គ ៗ ត្រាស់សួរថា "ម្នាលព្រាហ្មណ៍ អ្នកត្រូវការអ្វី ?" ។ ព្រាហ្មណ៍ជរាក្រាបទូលថា "បពិត្រព្រះរាជសម្ភារ ទូលព្រះបង្គំចាស់ជរាទីទ័លក្រណាស់ គ្មានអ្វីទទួលព្រះរាជទានទេ សូមទ្រង់ព្រះរាជ-ទានភោជន គ្រាន់ជាស្បៀងលៀងជីវិតតរៀងទៅ" ។ ព្រះរាជាទ្រង់បានប្រទានភោជន ដាក់ភាជន៍មាសទៅព្រាហ្មណ៍ជរា ៗ បានទទួលហើយត្រឡប់ជាគ្រវែងភោជនចោលទៅ ហើយពោលពាក្យទ្រគោះដាក់ព្រះអង្គថា "យើអើ ព្រះបាទអាទិត្តរាជ ម្តេចក៏ឲ្យភោជនអាក្រក់មកយើង ?" ហើយធ្វើហាក់ដូចជាខឹងខ្លាំងណាស់ តាំងបោកប្រាស់ដើរចៀសចេញទៅ ។ ឯព្រះមហាក្សត្រទុកជាទ្រង់បានស្តាប់សំដីមិនគប្បីដូច្នេះក៏ដោយ ក៏ឥតមានព្រះហឫទ័យក្រេវក្រោធបន្តិចឡើយ ត្រឡប់ជាមានព្រះភក្ត្រញញឹមប្រិមប្រិយ ដូចបទុមមាសកំពុងរីកទទួលសែងព្រះសូរ្យា ។

ឯឥន្ទព្រាហ្មណ៍ ត្រឡប់ប្រែកាយាជាព្រាហ្មណ៍កំឡោះមានរូបស្រស់បស់ត្រឡប់ចូលមករកព្រះអង្គទៀត បានថ្លែងសេចក្តីសំណេះសំណាលរាក់ទាក់ ក្រាបបង្គំទូលសួរសុខទុក្ខ ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាល ហើយទើបព្រាហ្មណ៍ក្រាបបង្គំទូលថា "បពិត្រព្រះរាជសម្ភារប្រសើរអើយ ទូលព្រះបង្គំមកនេះមានបំណងនឹងក្រាបទូលសូមព្រះរាជទេពីព្រះអង្គ សូមទ្រង់ព្រះរាជទានព្រះនាងសង្ខទេវី ដល់ទូលបង្គំជាខ្ញុំ ក្នុងកាលឥឡូវនេះកុំបីខានឡើយ" ។ ព្រះរាជាទ្រង់បានទតព្រះនេត្រទៅរកព្រះនាងទេវី ៗ ក្រាបទូលព្រះស្វាមីថា "បពិត្រព្រះស្វាមី ខ្ញុំម្ចាស់ជាទាសីរបស់ព្រះអង្គស្រាប់ ព្រះអង្គសព្វព្រះរាជហឫទ័យព្រះរាជទានខ្ញុំម្ចាស់ទៅជនណាមួយ សូមទ្រង់ព្រះរាជទានចុះ កុំបីទើសទាល់

ឡើយ” ។ ព្រះមហាក្សត្រទ្រង់យកទឹកកុណ្ឌី ជ្រួចប្រទានព្រះនាងដល់ព្រាហ្មណ៍នោះ មួយរំពេចហើយទ្រង់មានព្រះបន្ទូលថា “ម្នាលព្រាហ្មណ៍ ព្រះនាងសង្ខទេវី ជាទីស្រឡាញ់ពេញចិត្តស្មើដោយជីវិតរបស់យើង ប៉ុន្តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់ពេញចិត្តលើសលែងព្រះនាងទេវី ១ រយគុណ ១ ពាន់គុណទៅទៀត”។

ខណៈនោះ ប្រឹថពីកម្រើកញាប់ញ័រ ទាំងមហាសមុទ្រក៏កើតរលកបោកបែកផ្កាត្រែង ទាំងភ្នំសិនេរុរាជ ក៏ឱនលំទោនទោរទន់ទាំងទេវតា និងមហាព្រហ្មទាំងឡាយ ក៏នាំគ្នាថ្វាយព្រះពរស័ព្ទសាធុការទ្រហឹងអឺងកង ។

ព្រះឥន្ទ្រាធិរាជ ទ្រង់បានជ្រាបព្រះរាជអធ្យាស្រ័យនៃក្សត្រាក្សត្រីទាំងពីរអង្គ សុទ្ធតែទ្រង់ធមិ ទ្រង់មានព្រះទ័យសប្បុរស ប្រសើរក្រៃលែង ទ្រង់បានផ្លាស់ភេទជាព្រះឥន្ទ្រវិញហើយទ្រង់មានទេវឱង្ការថា “បពិត្រព្រះមហារាជ ទូលព្រះបង្គំមកនេះ ដើម្បីជួយបំពេញទានបារមីនៃព្រះអង្គប៉ុណ្ណោះ” ហើយទ្រង់ទូលសុំព្រះរាជទានអភ័យទោស បំពោះក្សត្រទាំងពីរព្រះអង្គហើយទ្រង់សំដែងទសពិធរាជធម៌ថ្វាយព្រះបាទអាទិត្តរាជ ទ្រង់ប្រទានឱវាទផ្សេង ៗ ទៀត ទ្រង់ប្រទានពរស័ព្ទសាធុការ ដោយប្រការផ្សេង ៗ ហើយស្ដេចទូលលាត្រឡប់ទៅកាន់ឋានទេវលោកវិញ ។

ឯព្រះបាទអាទិត្តរាជ ព្រមទាំងរាជវង្សានុវង្ស ទ្រង់គង់នៅក្នុងរាជសម្បត្តិ នានគរជេតុត្តរ ប្រកបដោយក្ដីសុខសុភមង្គល និងជោគជ័យសិរីសួស្ដីគ្រប់ប្រការ ដរាបដល់សោយទីវង្គត ទៅកាន់សុគតិភពជាទីមនោរម្យ សមដូចសេចក្ដីសប្បុរសដ៏ប្រសើរខ្ពង់ខ្ពស់របស់ព្រះអង្គគ្រប់ប្រការ ៕




**អៀង ហួយ EANG HUY**

**r s**

*មានលក់ដុំ និងលក់រាយ ហូល ផាមួង សារុង*
*គ្រប់ប្រភេទ ផលិតពីសាច់សូត្រសុទ្ធ*

*អាសយដ្ឋានទាក់ទងនៅប្រទេសកម្ពុជា ៖*

**ផ្សារអូឡាំពិក តូបលេខ B1 128 & 129**

**ទូរស័ព្ទលេខ ៖ 012–778 015 ឬ 011–625 246**

*អតិថិជននៅសហរដ្ឋអាមេរិក សូមទាក់ទង ៖*

កញ្ញា វុធ្យឌី ក្រុង Tacoma, Washington State.

ទូរស័ព្ទ ៖ 253–536 3020

(មានទទួលកាត់ដេរសម្លៀកបំពាក់ និងលក់ហូល ផាមួង)

## លិខិតរបស់និស្សិតខ្មែរម្នាក់នៅទីក្រុងព្រៃនគរ ផ្ញើរមកកាន់ព្រឹត្តិបត្រ កម្ពុជាក្រោម

ក្រុងព្រៃនគរ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០៤

លោកប្រធានជាទីគោរព !

ខ្ញុំបាទជានិស្សិតខ្មែរក្រោម សព្វថ្ងៃសិក្សានៅមហាវិទ្យាល័យទីក្រុងព្រៃនគរ កម្ពុជាក្រោម មានក្តីរំភើបរីករាយយ៉ាងក្រៃលែង ដែលបានដឹងច្បាស់នូវគោលការណ៍របស់សហព័ន្ធខ្មែរកម្ពុជាក្រោម បានធ្វើឡើងដើម្បីសេរីភាព និងសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងសម្រាប់ជនរួមឈាម ដែលកំពុងរស់នៅដោយទុក្ខវេទនា និងឈឺចាប់ក្រោមការគាបសង្កត់អំពីរដ្ឋផ្តាច់ការវៀតណាម ។

ឆ្លងតាមសារលិខិតនេះ សូមតាងនាមរូបខ្ញុំផ្ទាល់ ព្រមទាំងបងប្អូនជនរួមឈាមយើងនៅកម្ពុជាក្រោម សូមអរគុណ ដល់អស់លោក លោកស្រីយ៉ាងជ្រាលជ្រៅ ដែលកំពុងរួមកម្លាំងតស៊ូ ដើម្បីជាតិ សាសនា និងមាតុភូមិកម្ពុជាក្រោមជាទីស្នេហារបស់យើង ។

ខ្មែរជាជាតិសាសន៍មួយដ៏បវរ នៅអាស៊ីអាគ្នេយ៍ ត្រូវក្លាយជាបីចំណែក លើ ក្រោម និងកណ្តាល គួរឲ្យស្រណោះអនេក ។ ខ្មែរយើងត្រូវរងទុក្ខវេទនា ក្រោមការគាបសង្កត់ របស់បរទេសរាប់សតវត្សរមកហើយ ទុក្ខសោកទាំងអស់វាគ្រប់គ្រាន់ទៅហើយ ដល់ពេលដែលយើងត្រូវក្រោកឡើងសាមគ្គីទាមទារសិទ្ធិសេរីភាព និងសម្រេចវាសនាខ្លួនដោយខ្លួនឯងវិញហើយ ។

ឆ្លងតាមសហព័ន្ធខ្មែរកម្ពុជាក្រោម ខ្ញុំសូមអំពាវនាវដល់និស្សិតខ្មែរទូទាំងពិភពលោក ចូលរួមសាមគ្គី សហការជាមួយនឹងសហព័ន្ធ ដើម្បីទាមទារសិទ្ធិសេរីភាព និងរំដោះទឹកដីកម្ពុជាក្រោមឲ្យផុតពីអំណាចផ្តាច់ការរបស់យួន ។

ខ្ញុំជឿជាក់ថា ក្រោមការដឹកនាំរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម គ្រប់កិច្ចការទាំងឡាយនឹងបានសម្រេចជោគជ័យជាមិនខានឡើយ ។

សូមអស់លោកប្រកបដោយសុខភាពមាំមួនបញ្ញាវាងវៃ និងទទួលបានជោគជ័យគ្រប់ប្រការ ៕

សូមអស់ខ្មែរក្រោម ខិតខំម្នាម្នី
រួបរួមសាមគ្គី ស្មួយជាតិរួមគ្នា
ឲ្យផុតនឹមដែក រួចទុក្ខកម្មពៀរ
សែនសុខសោភា លើដីខ្មែរក្រោម ។

**ហ៊ូ សុទ្ធាវាស**

ព្រឹត្តិបត្រ **កម្ពុជាក្រោម**

# សួស្តីឆ្នាំថ្មី

**ឆ្នាំសកល ២០០៥**